ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ : ០៣១០ អក/ររដប

ថ្ងៃ... ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ,ថ្ងៃទី០៧ខែមេសា ឆ្នាំ២០២០

នាយកដ្ឋានបណ្តុះបណ្តាល
ចូល
លេខ ១៤១/២០ ម៉ោង.........
ថ្ងៃទី ០៧ ខែ ០៤ ឆ្នាំ ២០២០
បញ្ជូន.........

10/04/2020

# របាយការណ៍
## ស្តីពី
## សកម្មភាព និងលទ្ធផលការងារប្រចាំខែមីនា និងទិសដៅបន្ត សម្រាប់ខែមេសា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានរដ្ឋបាល

អគ្គនាយកដ្ឋានរដ្ឋបាល គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំង១១ ចំណុះក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការឱ្យក្រសួង ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលក្នុងការបង្កើត ការចុះបញ្ជី និងគ្រប់គ្រងសកម្មភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

ក្នុងខែមីនា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តការងារតាមតួនាទី ភារកិច្ច ដោយសម្រេចលទ្ធផលបានដូចខាងក្រោម៖

### I-សកម្មភាពការងារ និងលទ្ធផល

#### ១-ការងារលិខិតស្នាម និងឯកសារផ្សេងៗ

-បានទទួលលិខិត និងឯកសារ ដែលបញ្ជូនមក ពីអគ្គលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះ ក្រសួងមហាផ្ទៃ សរុបចំនួន ៥.៧៩១ច្បាប់ និងបា នធ្វើការបែងចែកជូនទៅនាយកដ្ឋានចំណុះរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៤០៤ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៦៩ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១៤២ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ៣១ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៦២ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៣៨៣ច្បាប់។

-បានទទួលលិខិតមកពីនាយកដ្ឋានជំនាញចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមានចំនួន ៣៩២ច្បាប់ ដែលក្នុងនោះមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ១៤៨ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ១៥ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៨៩ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ៤២ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៣៧ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៦១ច្បាប់ ដើម្បីដាក់ជូនអគ្គនាយកជ្រាបជារបាយការណ៍ និងពិនិត្យសម្រេច។

-បានចាត់ចែងបញ្ជូនឯកសារចំនួន ២៦១ច្បាប់ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងជ្រាបជារបាយការណ៍និងពិនិត្យ សម្រេច ដែលក្នុងនោះឯកសារមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៩៨ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ០៩ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៥៩ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ១១ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ២០ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៤៥ច្បាប់។

-បានទទួលឯកសារចំនួន១៨៣ច្បាប់ ដែលថ្នាក់ដឹកនាំក្រសួងមហាផ្ទៃពិនិត្យ សម្រេចរួច និងបញ្ជូនទៅនាយកដ្ឋានចំណុះ ដើម្បីចាត់ចែងបន្តរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន **៦៤ច្បាប់** នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន **០៧ច្បាប់** នាយកដ្ឋានបុគ្គលិកចំនួន **៥២ច្បាប់** នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន ០៨ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន **១៧ច្បាប់** និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៣៥ច្បាប់។

**២-ការងារចេញលិខិតបង្គាប់ការ និង លិខិតបញ្ជាបេសកកម្ម**

ក្នុងខែមីនា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានចេញលិខិតបង្គាប់ការ និងលិខិតបញ្ជាបេសកកម្មសរុបចំនួន ៣០០ច្បាប់ ក្នុងនោះ លិខិតបង្គាប់ការចំនួន ១៧៨ច្បាប់ និងលិខិតបញ្ជាបេសកកម្មចំនួន ១២២ច្បាប់ ជូនថ្នាក់ដឹកនាំ និងមន្ត្រីចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះទៅបំពេញបេសកកម្មនៅតាមបណ្ដាខេត្តនានា។

ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានចុះទិដ្ឋាការជូនមន្ត្រីរាជការមកពីបណ្ដាខេត្តដែលមកបំពេញបេសកកម្មនៅក្រសួងមហាផ្ទៃផងដែរ។

**៣-ការងារប្រជុំ និងសិក្ខាសាលាផ្សេងៗ**

ក្នុងខែមីនា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាល បានរៀបចំកិច្ចប្រជុំ និងចាត់មន្ត្រីចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត វេទិកា និងកម្មវិធីនានាដូចខាងក្រោម៖

-ចូលរួមជាមួយ **ឯកឧត្តម ម៉ុន ហុន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ** ក្នុងឱកាសជំនួបពិភាក្សាការងារជាមួយអង្គការមូលនិធិកុមារកម្ពុជា។

▪ **ការប្រជុំ សិក្ខាសាលា៖**

-ដឹកនាំកិច្ចប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្ដីព្រាងប្រកាសអន្តរក្រសួង ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរសុខាភិបាលរាជធានី ខេត្ត

-ដឹកនាំកិច្ចប្រជុំស្ដាប់របាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តគម្រោងរបស់អង្គការវ៉េតជីសេដ និងផែនការយុទ្ធសាស្ត្ររបស់អង្គការ ឆ្នាំ២០២០

-ដឹកនាំកិច្ចប្រជុំគណៈកម្មការដើម្បីជ្រើសរើសទីប្រឹក្សាអន្តរជាតិផ្នែកអភិវឌ្ឍជំនាញរបស់គម្រោង LEAP

-ចូលរួមកិច្ចប្រជុំស្ដីពីការរៀបចំសេចក្ដីសម្រេចរួមឆ្នាំ២០២០ និងបិទសេចក្ដីសម្រេចរួមឆ្នាំ២០១៩ រវាងលេខាធិការដ្ឋានគ.ជ.អ.ប ជាមួយក្រសួងស្ថាប័ន

-ចូលរួមកិច្ចប្រជុំស្ដាប់សេចក្ដីរាយការណ៍ក្នុងការរៀបចំកញ្ចប់ឯកសារកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ «២០២០-២០៣០» និងការរៀបចំឯកសារក្របខណ្ឌគតិយុត្តសម្រាប់ដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម

-ចូលរួមកិច្ចប្រជុំធ្វើសេចក្ដីព្រាងច្បាប់ វិសោធនកម្មច្បាប់ស្ដីពីអន្តោប្រវេសន៍និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា

-ចូលរួមកិច្ចប្រជុំបន្តដើម្បីពិនិត្យពិភាក្សាសំណើ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិលក្នុងការធ្វើវិសោធនកម្មច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-ចូលរួមកិច្ចប្រជុំស្ដីពីកិច្ចសហប្រតិបត្តិការ ឆ្នាំ២០២០ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈឡាវ នៅទីក្រុងវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាមានិតឡាវ

-ចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាជាមួយក្រសួងពាក់ព័ន្ធអំពីការកំណត់ធនធានហិរញ្ញវត្ថុសម្រាប់ផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅលេខាធិការដ្ឋាន (គ.ជ.អ.ប)

-ចូលរួមកិច្ចប្រជុំអន្តរក្រសួងចង្អៀតនៅទីស្ដីការគណៈរដ្ឋមន្ត្រីពិភាក្សាលើសំណើរបស់ក្រសួងកសិកម្មស្នើដាក់បញ្ចូលមាត់ច្រកទ្វារអូរបីជាន់ ទៅជាទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែន ស្ថិតនៅភូមិប្រាសាទ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

-ចូលរួមកិច្ចប្រជុំលើកទី៣ របស់គណៈកម្មការប្រឹក្សាភិបាលនៃកម្មវិធី (ACESS) លើសកម្មភាពពិការភាព និងអំពើហិង្សាលើស្ត្រី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ

-ចូលរួមកិច្ចប្រជុំក្រុមបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ក.ប.ស.ហ) លើកទី៦ នៅធនាគារជាតិ នៃកម្ពុជា

-ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសេចក្ដីសម្រេចស្ដីពីការកែសម្រួលសមាសភាពក្រុមការងារសហប្រតិបត្តិការមេគង្គ-ឡានឆាង (LMC) ក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំពិភាក្សាលើការរៀបចំដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលក្នុងឆ្នាំ២០២០ ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ

-ចូលរួមកិច្ចប្រជុំអន្តរក្រសួងស្ដីពី «ការកំណត់តំបន់ធម្មជាតិ ដែលត្រូវស្នើដាក់បញ្ចូលក្នុងបញ្ជីត្រៀមបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ» នៅទីស្ដីការក្រសួងបរិស្ថាន

-ចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងសំណើវិធានការអនុវត្តលើការរំលោកកាន់កាប់ដីព្រៃឈើ នៅទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ចូលរួមកិច្ចប្រជុំពិភាក្សា ស្ដីពីការដោះស្រាយផលប៉ះពាល់ដែលនៅសេសសល់ក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន Union Development Group Co.,Ltd នៅទីស្ដីការក្រសួងបរិស្ថាន

-ចូលរួមកិច្ចប្រជុំពិភាក្សា ស្ដីពីការបង្កើតក្រុមប្រឹក្សាផ្ដល់យោបល់ក្នុងវិស័យស្រូវអង្ករ នៅទីស្ដីការក្រសួងពាណិជ្ជកម្ម ដែលរៀបចំដោយក្រសួងក្រសួងពាណិជ្ជកម្ម

-ចូលរួមកិច្ចប្រជុំក្រុមគាំទ្រ និងសម្របសម្រួលគម្រោងនៃគម្រោងអភិបាលកិច្ចប្រកបដោយបរិយាប័ន្នសម្រាប់ការផ្ដល់សេវា និងគណនេយ្យភាពសង្គម

-ចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរ នៅទីស្ដីការគណៈរដ្ឋមន្ត្រី

-ចូលរួមកិច្ចប្រជុំជាមួយអង្គការតស៊ូមតិ និងគោលនយោបាយ (API) និងអង្គការ Instedd អំពីការសិក្សាដើមគ្រាពាក់ព័ន្ធនឹងការយល់ដឹង ក៏ដូចជាការប្រើប្រាស់សេវាការិយាល័យច្រកចេញចូលតែមួយរបស់ប្រជាពលរដ្ឋនៅស្រុក គោលដៅចំនួន ០៥នៃខេត្តបាត់ដំបង

-ចូលរួមសិក្ខាសាលាស្ដីពី «បទពិសោធន៍ក្នុងការប្រើអក្សរឡាតាំងសម្រាប់កត់សូរភាសាខ្មែរ និងបញ្ហាគោលការណ៍ក្នុងការប្រើអក្សរឡាតាំងសម្រាប់កត់សូរខ្មែរ» នៅរាជបណ្ឌិត្យសភាកម្ពុជា រៀបចំដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងឯកសារបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពីការចិញ្ចឹមកូនបែបវិជ្ជមាន

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងចុងក្រោយផែនការសកម្មភាពជាតិស្ដីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៩-២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា

-ចូលរួមសិក្ខាសាលាស្ដីពី«នីតិវិធីលទ្ធកម្មសាធារណៈ និងការអនុវត្តផែនការសកម្មភាពលម្អិតMAP3 សម្រាប់ឆ្នាំ២០២០» នៅខេត្តសៀមរាប។

- កម្មវិធីផ្សេងៗ៖

-ចូលរួមពិធីប្រកាសចូលកាន់មុខតំណែងរបស់អភិបាល អភិបាលរងនៃគណៈអភិបាលខេត្តកណ្ដាល និងខេត្តក្រចេះ

-ចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់រដ្ឋបាលរាជធានីខេត្ត ចំនួន២៣ លើកលែងខេត្ត (ខេត្តកំពត តាកែវ) ដែលប្រកាសក្រុមការងារថ្នាក់ជាតិលើកពេលដោយសារការរីករាលដាលជំងឺកូវីដ១៩

-ចូលរួមពិធីមិទីញអបអរសាទរទិវាអន្តរជាតិ៨មីនា ឆ្នាំ២០២០ ខួបលើកទី១០៩ ក្រោមប្រធានបទ (មានសន្តិភាព មានការលើកកម្ពស់សមាសភាពយេនឌ័រ) របស់ក្រសួងមហាផ្ទៃ

-ចូលរួមពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

-ចូលរួមកិច្ចសន្ទនាគោលនយោបាយថ្នាក់ជាតិស្តីពី ការជំរុញសេវាសាធារណៈឃុំ ពង្រឹងការចូលរួម និងលើកកម្ពស់សមភាពយេនឌ័រ

-ចូលរួមក្នុងសន្និសីទ ស្តីពីការផ្សព្វផ្សាយនីតិវិធីលទ្ធកម្មដេញថ្លៃជ្រើសរើសក្រុមហ៊ុនផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ

-ចូលរួមជាគណៈអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នា រវាងសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាមួយសាលាភូមិន្ទរដ្ឋបាល

-ចូលរួមវេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៧២ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

**៤-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

**៤.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុង**

**៤.១.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន**

-អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ។

-សេចក្តីណែនាំលេខ ០០៣ សណន ចុះថ្ងៃ១៩ ខែមីនា ឆ្នាំ២០២០ ស្តីពីវិធានការបង្ការទប់ស្កាត់ការឆ្លងរាតត្បាតជំងឺ(COVID-19)។

**៤.១.២-លិខិតបទដ្ឋានគតិយុត្តដែលកំពុងរៀបចំ**

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ ការកែសម្រួល និងការកំណត់ឈ្មោះរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ

-សេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពីការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីការវាយតម្លៃជ្រើសរើសការិយាល័យច្រកចេញចូលតែមួយដែលមានស្នាដៃល្អនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក

-សេចក្តីព្រាងសៀវភៅណែនាំ ស្តីពី "កិច្ចការរដ្ឋបាល" សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា (ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

### ៤.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

#### ៤.២.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន

-អនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវថ្ងៃទី១៦ ខែមីនា ២០២០ស្តីពីការកែសម្រួល និងដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិលឆ្នាំ២០២០

-អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ស្តីពីការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ។

#### ៤.២.២-លិខិតបទដ្ឋានគតិយុត្តកំពុងសហការរៀបចំ

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលរាជធានី ខេត្ត

-សេចក្តីព្រាងរៀបចំកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងរៀបចំកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤៣ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិកាឯកភាពលើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីនីតិវិធី នៃការចុះបញ្ជីសិប្បកម្មដែលមានដើមទុនសមមូលលើសពី៨០លារៀលដល់២០០.០០០.០០០រៀល និងគ្មានហានិភ័យ

-សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាល ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មរបស់DMF

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩-២០៣០។

### ៥-ការងារបុគ្គលិក

#### ៥.១-ការងារក្របខ័ណ្ឌ

គិតត្រឹមខែមីនា ឆ្នាំ២០២០ ស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃសរុបមានចំនួន ២៩.៧៦៩រូប/ស្រី៩.៩២៦រូប (ក្នុងនោះក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ១.០០៥រូប/ស្រី២៤២រូប ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិចំនួន ២៥.៦៣៦រូប/ស្រី៩.២១៨រូប ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ជាតិចំនួន ១.១៧៥រូប/ស្រី១៩០រូប ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ក្រោមជាតិចំនួន ១.៩៥៣រូប/ស្រី ២៧៦រូប) បើប្រៀបធៀបទៅនឹងខែកុម្ភៈ ឆ្នាំ២០២០ ក្របខ័ណ្ឌថយចុះចំនួន ០១រូប។ ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃ ក៏បានបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលចំនួន ០៣រូប ក្របខ័ណ្ឌចេញចំនួន ០៤រូប(ក្នុងនោះផ្ទេរទៅក្នុងក្របខ័ណ្ឌក្រសួងនានាចំនួន ០៣រូប និងលុបឈ្មោះដោយមរណភាពចំនួន ០១រូប)។

**៥.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល**

ក្នុងខែមីនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យមន្ត្រីរាជការឈប់សម្រាកពីការងារ និងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សសរុបចំនួន ០៨រូប/ស្រី០៧រូប(ក្នុងនោះសម្រាកលំហែមាតុភាពចំនួន ០៧រូប និងសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ០១រូប)។ ទន្ទឹមនោះ ថ្នាក់ដឹកនាំក្រសួង ក៏បានផ្តល់គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួន២៧៦គ្រឿង ក្នុងនោះ គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ចំនួន ៩៦គ្រឿងរួមមាន៖ (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០១គ្រឿង ថ្នាក់មហាសេនាចំនួន ០៥គ្រឿង ថ្នាក់ធិបឌិន្ទចំនួន ៣៥គ្រឿង ថ្នាក់សេនាចំនួន១៩គ្រឿង និងថ្នាក់អស្សឫទ្ធិចំនួន៣៦គ្រឿង) គ្រឿងឥស្សរិយយសុវត្ថារាថ្នាក់អស្សឫទ្ធិចំនួន ០១គ្រឿង គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌតាមលំដាប់ថ្នាក់ចំនួន ១០គ្រឿង រួមមាន៖(ថ្នាក់មហាសេរីវឌ្ឍន៍ ចំនួន ០៤គ្រឿង ថ្នាក់មហាសេនាចំនួន ០៣គ្រឿង ថ្នាក់សេនាចំនួន ០១គ្រឿង និងថ្នាក់អស្សឫទ្ធិចំនួន ០២គ្រឿង)និងមេដាយការងារតាមលំដាប់ថ្នាក់ចំនួន ១៦៩គ្រឿង រួមមាន៖ (ថ្នាក់មាសចំនួន៦១គ្រឿង ថ្នាក់ប្រាក់ចំនួន៤៨គ្រឿង ថ្នាក់សំរឹទ្ធចំនួន៦០គ្រឿង)។

**៥.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

ក្នុងខែមីនា ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិលតាមមុខតំណែង ដែលកំពុងបម្រើការងារនៅគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃសរុបចំនួន១.០០៥រូប/ស្រី២៤២រូប ស្មើនឹង ២៤.០៧% ដែលក្នុងនោះរួមមាន៖

-មន្ត្រីរាជការស៊ីវិលចំនួន ៩៨៦រូប/ស្រី ២៤១រូប ស្មើនឹង ២៤,៤៤% ក្នុងនោះរួមមាន (រដ្ឋលេខាធិការចំនួន ០៣រូប អនុរដ្ឋលេខាធិការចំនួន ០៣រូប/ស្រី០១រូប អគ្គនាយកចំនួន ០១រូប អគ្គនាយករងចំនួន ២៧រូប/ស្រី០២រូប អគ្គលេខាធិការរងចំនួន ០៤រូប/ស្រី០១រូប គណៈកម្មាធិការ គ.ជ.ប.ទ ចំនួន ០៣រូប (ក្នុងនោះសមាជិកគណៈកម្មធិការចំនួន ០១រូប ប្រធានលេខាធិការដ្ឋានចំនួន ០១រូប អនុប្រធានលេខាធិការដ្ឋានចំនួន០១រូប ) ក្រុមប្រឹក្សានីតិកម្មចំនួន ០៧រូប/ ស្រី ០២រូប (ក្នុងនោះប្រធានចំនួន ០១រូប អនុប្រធានចំនួន ០៣រូប/ស្រី០១រូប សមាជិកចំនួន ០៣រូប/ស្រី ០១រូប) លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)ចំនួន១៧រូប/ស្រី០៦រូប អគ្គាធិការចំនួន ០១រូប អគ្គាធិការរងចំនួន ០៥រូប/ស្រី ០១រូប ប្រធាននាយកដ្ឋានចំនួន ១២រូប/ ស្រី០១រូប អនុប្រធាននាយកដ្ឋានចំនួន ១៣១រូប/ស្រី២៩រូប ប្រធានការិយាល័យចំនួន ៨៤រូប/ស្រី១៩រូប អនុប្រធានការិយាល័យចំនួន២៥១រូប/ស្រី ៧១រូប និងមន្ត្រីចំនួន ៣៩៣រូប/ស្រី ១១៣រូប។

-មន្ត្រីដែលផ្ទេរភារកិច្ចពីថ្នាក់ក្រោមជាតិមកទីស្តីការក្រសួងចំនួន ១៩រូប/ស្រី០២រូប ស្មើនឹង១០,៥២%

-មន្ត្រីរាជការក្របខ័ណ្ឌដែលមានមុខតំណែងជាទីប្រឹក្សា និងជំនួយការចំនួន ៥៥៣រូប/ស្រី៥៦រូប ស្មើនឹង ១០,១២%។ ដោយឡែកក្នុងខែមីនា ឆ្នាំ២០២០នេះ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃបានពិនិត្យ សម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ផ្លាស់ប្តូរកន្លែងធ្វើការ ជូនមន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិសរុបចំនួន ៤៧រូប/ស្រី០៧រូប។

**៥.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

គិតត្រឹមខែមីនា ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសមានដូចខាងក្រោម ៖

-គណៈអភិបាលរាជធានី ខេត្តសរុបចំនួន១៧៥រូប/ស្រី២៧រូប ស្មើនឹង១៥,៤២% ក្នុងនោះ(អភិបាលរាជធានី ខេត្តចំនួន ២៥រូប/ស្រី០១រូប អភិបាលរងរាជធានី ខេត្តចំនួន ១៥០រូប/ស្រី២៦រូប)

-គណៈអភិបាលក្រុង ស្រុក ខណ្ឌសរុបចំនួន៩៣៨រូប/ស្រី១៩៨រូប ស្មើនឹង២១.១១% ក្នុងនោះ(អភិបាលក្រុង ស្រុក ខណ្ឌចំនួន ២០៣រូប/ស្រី០៧រូប អភិបាលរងក្រុង ស្រុក ខណ្ឌចំនួន ៧៣៥រូប/ស្រី ១៩១រូប)

-មន្ត្រីស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន ៦.៤៨៩រូប/ស្រី ២.១៥២រូប ស្មើនឹង ៣៣.១៦% ក្នុងនោះ (សាលារាជធានី ខេត្តចំនួន ២.៨០៩រូប/ស្រី៩១៥រូប ស្មើនឹង ៣២.៥៧% សាលាក្រុង

ស្រុក ខណ្ឌសរុបចំនួនចំនួន ៣.៦៨០រូប/ស្រី១.២៣៧រូប ស្មើនឹង ៣៣,៦១%) និងប្រធានទីស្នាក់ការច្រកទ្វារព្រំដែនចំនួន ៥៤រូប ។ ទន្ទឹមនេះដែរ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃក៏បានពិនិត្យ សម្រេចតែងតាំងមុខតំណែងប្រគល់ភារកិច្ចជូនអភិបាល អភិបាលរង នៃគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុក ខណ្ឌ និងផ្លាស់ប្តូរភារកិច្ច និងតែងតាំងស្មៀនឃុំ សង្កាត់ចំនួន ២៩រូប/ស្រី០៣រូប (ដូចក្នុងឧបសម្ព័ន្ធ១ក-១ឃ)។

**៥.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ស្ថានភាពបច្ចុប្បន្នភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ទូទាំងប្រទេសមានដូចខាងក្រោម៖

-សមាសភាពក្រុមប្រឹក្សារាជធានី ខេត្តសរុបចំនួន ៥៥៩រូប/ស្រី ៩៥រូប (ស្មើនឹង ១៦,៩៩%) ក្នុងនោះ (ប្រធានក្រុមប្រឹក្សារាជធានី ខេត្តចំនួន ២៥រូប សមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន ៥៣៤រូប/ស្រី ៩៥រូប)។

-សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសរុបចំនួន ៣.៥៥៥រូប/ស្រី៦២១រូប (ស្មើនឹង១៧,៤៩%)ក្នុងនោះ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ២០៣រូប/ស្រី០៥រូប សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ៣.៣៥២រូប/ស្រី៦១៦រូប។

-សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន ១១.៥៧២រូប/ស្រី២.៣៧៧រូប(ស្មើនឹង២០.៥៤%)(ក្នុងនោះ មេឃុំចំនួន ១.៤០៥រូប/ស្រី ១១០រូប ចៅសង្កាត់ចំនួន ២៤១រូប/ស្រី ២៦រូប ជំទប់ទី១ ចំនួន ១.៤០៥រូប/ស្រី ២២៥រូប ជំទប់ទី២ចំនួន ១.៤០៥រូប/ស្រី៣០៨រូប ចៅសង្កាត់រងទី១ ចំនួន ២៤១រូប/ស្រី ៦១រូប ចៅសង្កាត់រងទី២ចំនួន ២៤១រូប /ស្រី៥៣រូប និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៦.៦៣៤រូប/ស្រី១.៥៩៤រូប)។ ក្នុងខែមីនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ចំនួន ១២រូប/ស្រី០៣រូប ក្នុងនោះសមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន ០១រូប/(ដូចក្នុងឧបសម្ព័ន្ធ២ក) សមាសភាពសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ០៤រូប/ស្រី០២រូប (ដូចក្នុងឧបសម្ព័ន្ធ២ខ) និង សមាសភាពសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ចំនួន ០៧រូប/ស្រី០១រូប(ដូចក្នុងឧបសម្ព័ន្ធ២គ)។

**៥.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

ស្ថានភាពបច្ចុប្បន្នភាព នៃចំនួនប្រវត្តិរូបមន្ត្រីរាជការស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យសរុបចំនួន ៩.៨៧៩រូប/ស្រី ២.៧៨០រូប(ក្នុងនោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ៨៨៩រូប/ស្រី ២០១រូប និងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិចំនួន ៨.៩៩០រូប/ស្រី២.៥៧៩រូប)។

**៦-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៦.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

ក្នុងខែមីនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានចាត់បញ្ជូនមន្ត្រីរាជការស៊ីវិលចំនួន ០៣រូប/ស្រី០១រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសផ្តល់ការបណ្តុះបណ្តាល " Training Delivery Technique " នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ។ ទន្ទឹមនោះ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានរៀបចំវគ្គបណ្តុះបណ្តាលមួយចំនួនដូចខាងក្រោម៖

-វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់ក្រុមគ្រូបង្គោលនៅថ្នាក់ជាតិ មានសិក្ខាកាមចំនួន ១៨រូប/ស្រី០៥រូប នៅសណ្ឋាគារភ្នំពេញ។

-វគ្គបណ្តុះបណ្តាលស្តីពីការអប់រំភាពជាអ្នកដឹកនាំ ដែលមានសិក្ខាកាមចូលរួមសរុប ២២រូប/ស្រី១៣រូប ដែលសហការរៀបចំជាមួយអង្គការវ៉ តើធីសេដ (WaterSHED)

-វគ្គតម្រង់ទិសសម្រាប់ក្រុមគោលដៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅតាមបណ្តារាជធានី ខេត្ត២៥ ទូទាំងប្រទេសដែលមានសិក្ខាកាមចូលរួមសរុប ៤៨០០រូប/ស្រី៧២០រូប។

**៦.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

ក្នុងខែមីនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានរៀបចំសំណើសុំលិខិតឆ្លងដែនផ្លូវការចំនួន ០១ច្បាប់ ជូនអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលជាន់ខ្ពស់ ស្តីពីអភិបាលកិច្ចតំបន់ទីប្រជុំជន នៅប្រទេសសិង្ហបុរី។

**៦.៣-ការងារព័ត៌មាន និងផ្សព្វផ្សាយ**

ចំពោះការងារព័ត៌មាន និងផ្សព្វផ្សាយ អគ្គនាយកដ្ឋានរដ្ឋបាលបាន និងកំពុងរៀបចំសេចក្តីព្រាងព្រឹត្តិបត្រ វិមជ្ឈការ និងវិសហមជ្ឈការលេខ០៤,បន្តធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដោយបានបញ្ចូលអត្ថបទចំនួន ២១ករណី និងបានបន្តរៀបចំចាត់ចែងចងក្រងឯកសារដើម្បីបង្ហោះក្នុងTelegram Channel របស់អគ្គនាយកដ្ឋានរដ្ឋបាល។ លើសពីនេះ ក៏បានផ្សព្វផ្សាយសេចក្តីជូនដំណឹងមួយចំនួនស្តីពី៖

-ការទទួលពាក្យសំណើគម្រោងក្រោមកម្មវិធីសហប្រតិបត្តិការបណ្តាញជាសាកលឆ្នាំ ២០២០ (2020K-City Network Global Cooperation Program) របស់ក្រសួងដែនដីហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូនកូរ៉េ

-ការជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ទៅសិក្សានៅប្រទេសហ្វីលីពីន សម្រាប់ឆ្នាំសិក្សា២០២០

-ការប្រឡងអាហារូបករណ៍ "Australia Awards Scholarships intake2021" របស់រដ្ឋាភិបាលអូស្ត្រាលី

-អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមកម្មវិធីអាហារូបករណ៍ KOICA ទៅសិក្សានៅសាធារណរដ្ឋកូរ៉េ សម្រាប់ឆ្នាំសិក្សា២០២០។

**៧-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ**

**៧.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍**

ក្នុងកិច្ចគាំទ្របច្ចេកទេស និងអន្តរាគមន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំលិខិតក្នុងនាមក្រសួងមហាផ្ទៃ ជម្រាបជូនទៅក្រសួង ស្ថាប័ន និងបានដាក់ចេញនូវគោលការណ៍ណែនាំដល់រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពចំណុះក្រសួង ដូចខាងក្រោម៖

-រដ្ឋបាលរាជធានីភ្នំពេញ ករណីឈ្មោះ ខូវ ម៉េង និងឈ្មោះ កែ គុយហ៊ាង ស្នើសុំអន្តរាគមន៍ជួយដោះស្រាយចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលមានទីតាំងផ្ទះលេខ១០៧អា និងផ្ទះលេខ១០៨អា ផ្លូវ៧០ ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-រដ្ឋបាលរាជធានី ខេត្ត ករណីស្ថានទូតជប៉ុនប្រចាំកម្ពុជាស្នើសុំរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់ជនជាតិជប៉ុនក្នុងករណីមានផ្ទុកជំងឺ Coronavirus ឬ Covid-19 នៅកម្ពុជា។

-រដ្ឋបាលខេត្តកំពង់ស្ពឺ ករណីស្នើសុំអនុញ្ញាតដើម្បីប្រើប្រាស់និមិត្តសញ្ញាខេត្តជាផ្លូវការក្នុងកម្មវិធីបុណ្យជាតិ អន្តរជាតិផ្សេងៗរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ។

-រដ្ឋបាលខេត្តប៉ៃលិន ករណីរាជរដ្ឋាភិបាលអនុញ្ញាតឱ្យរដ្ឋបាលខេត្តប៉ៃលិន សាងសង់ស្តូបមិត្តភាពកម្ពុជា-វៀតណាម។

-រដ្ឋបាលខេត្តព្រះសីហនុ ករណី៖

- ឈ្មោះ អ៊ុង សាមី, ទៀប ហ៊ន, ទេព កឿន, សុខ សិរីវុធ, ខឹមជា សាឃឿន, លឹម ឡេន, ច្រឹក យឹន, យិន-ស្រិន, ឡូញ វណ្ណៈ, ទៀ សមស័ក្តិ និងឈ្មោះ ម៉ៅ ឈុន ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុជួយពន្លឿនលិខិតលេខ ៥១៣/១៨ សជណ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពីចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ និងអង្កេតដីទំហំ ៣២ហិកតា សម្រាប់ចុះបញ្ជីក្បាលដី និងកសាងប័ណ្ណកម្មសិទ្ធិ ស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

•ឈ្មោះ ផយ ម៉េងអាន, យន កុសល, វ៉ាន់ សារ៉េត, មូល ស៊ីនួន, ជឹម ប៊ុនលាង, មឿន វ៉ាន់ដេត, ស្រ៊ុន កាំង ហេង, ឡុង មិថុនា, សាន សំណាង និងឈ្មោះ ឃឹម ហួត ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុ ចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង និងកំណត់ព្រំដីទំហំ ២៦ហិកតា ៦៧អា ស្ថិតនៅភូមិពូជឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដើម្បីចុះបញ្ជីក្បាលដី ចេញប័ណ្ណកម្មសិទ្ធិ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិសាជាថ្មី។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណី៖

•សេចក្តីរាយការណ៍របស់គណបក្សកសិករ ដែលបានលើកឡើងអំពីភាពអសកម្មរបស់អភិបាលក្រុងប៉ោយប៉ែត ក្នុងការដោះស្រាយវិវាទដីធ្លីរបស់ឈ្មោះ នួន ស្រី ដែលមានដីកម្មសិទ្ធិទំហំ ២០០ម៉ែត្រការ៉េ ស្ថិតនៅភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

•ក្រុមអនាធិបតេយ្យធ្វើសកម្មភាពរំលោភចូលកាន់កាប់ដីរដ្ឋ និងដីកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋស្ថិតនៅក្នុងភូមិសាស្រ្តស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

•ឈ្មោះ សួន ឆេត តំណាងប្រជាពលរដ្ឋ ២៨៦គ្រួសារ សំណើសុំដីសម្បទានសង្គមកិច្ចទំហំ ១១ហិកតា សម្រាប់ចែកជូនប្រជាពលរដ្ឋក្រីក្រ និងខ្វះទីជំរកចំនួន ២៨៦គ្រួសារ ស្ថិតនៅចំណុចចាន់គិរី សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តព្រៃវែង ករណីធ្វើសេចក្តីរាយការណ៍អំពីការដោះស្រាយវិវាទប្រឡាយទឹក តា ហ៊ុយ ស្ថិតនៅឃុំត្រពាំងតាយ៉ង ឃុំកំពង់ប្រាសាទ និងឃុំឬស្សីស្រុក ស្រុកពាមជរ និងប្រឡាយទឹកចំនួន ០៣ខ្សែទៀតមានប្រឡាយទឹកភូមិឈើទាល ប្រឡាយទឹកភូមិតដ្ឋ និងប្រឡាយទឹកភូមិពេន។

-រដ្ឋបាលខេត្តកំពង់ចាម ករណីសំណើសុំការអនុញ្ញាតសាងសង់អគារសភាពាណិជ្ជកម្មខេត្តកំពង់ចាម និងខេត្តមណ្ឌលគិរី ដែលមានទំហំ ១០ម x ២០មក្នុងបរិវេណសាលាខេត្តកំពង់ចាម។

**-រដ្ឋបាលខេត្តកំពង់ចាម ឧត្តរមានជ័យ ព្រះវិហារ កំពង់ធំ បន្ទាយមានជ័យ មណ្ឌលគិរី ព្រៃវែង ស្វាយរៀង កំពត ប៉ៃលិន រតនគិរី ក្រចេះ និងខេត្តកោះកុង** ករណីអំពីសមាសភាពអធិបតី និងការរៀបចំពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី ខេត្ត និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។

**-អគ្គស្នងការដ្ឋាននគរបាលជាតិ** ករណីសំណើសុំធ្លាក់ត្រាមូលទឹកថ្មីចំនួន ០២គ្រឿង (ក្នុងនោះជូនរដ្ឋបាលឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាមចំនួន ០១គ្រឿង និង ជូនការិយាល័យសុខាភិបាលស្រុក ប្រតិបត្តិស្នួល នៃមន្ទីរសុខាភិបាលខេត្តក្រចេះចំនួន ០១គ្រឿង)។

ជាមួយគ្នានេះផងដែរក៏បានចាត់មន្ត្រីឱ្យចូលរួមសហការ គាំទ្រ និងរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី ខេត្ត និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន នៅរដ្ឋបាលរាជធានី ខេត្ត។

### ៧.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន ០១ ខេត្ត២៤ ក្រុង២៧ ស្រុក១៦២ ខណ្ឌ១៤ ឃុំ១.៤០៥ សង្កាត់២៤១ និងភូមិចំនួន ១៤.៣៨៤។ ក្នុងខែមីនា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃក៏បានធ្វើលិខិតជម្រាបជូនទៅរដ្ឋបាលរាជធានីភ្នំពេញ និងខេត្តកណ្តាល ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល ដោយកាត់យកផ្ទៃដីទំហំ ៣៧៦ហិកតា ពីក្រុងតាខ្មៅ ខេត្តកណ្តាលមកឱ្យក្រោមការគ្រប់គ្រងរបស់ខណ្ឌដង្កោ រាជធានីភ្នំពេញ។

### ៧.៣-ការងារផ្តល់គោរម្យងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ

ក្រសួងមហាផ្ទៃបានលើកសំណើជូនរាជរដ្ឋាភិបាលកម្ពុជា ករណីស្នើសុំគោរម្យងារឧកញ៉ាចំនួន ០២រូប មេដាយព្រះរាជាណាចក្រកម្ពុជាចំនួន ០២គ្រឿង (ថ្នាក់សេនាចំនួន ០១គ្រឿងនិង អស្សឫទ្ធិចំនួន ០១គ្រឿង) មេដាយមុនីសារាភ័ណ្ឌចំនួន ០៤គ្រឿង ( ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៣គ្រឿង ថ្នាក់មហាសេនាចំនួន ០១គ្រឿង ) មេដាយស្ថាបនាជាតិចំនួន ៣៩គ្រឿង (មេដាយមាសស្ថាបនាជាតិចំនួន ០៩គ្រឿង មេដាយប្រាក់ចំនួន ០៨គ្រឿង និងមេដាយសំរិទ្ធស្ថាបនាជាតិចំនួន ២២គ្រឿង) មេដាយការងារចំនួន ០៤គ្រឿង(មេដាយមាសការងារចំនួន ០១គ្រឿង

មេដាយប្រាក់ការងារចំនួន ០២គ្រឿង និងមេដាយសំរិទ្ធិការងារចំនួន ០១គ្រឿង) ដើម្បីផ្តល់ជូនសប្បុរសជនដែលបានជួយកសាងសមិទ្ធផលជាច្រើននៅខេត្តត្បូងឃ្មុំ កំពង់ចាម ស្វាយរៀង និងខេត្តព្រៃវែង ដោយចំណាយអស់ថវិកាសរុបចំនួន ១.៥៦៦.៨៥៦ដុល្លារ (មួយលានប្រាំរយហុកសិបប្រាំមួយពាន់ប្រាំបីរយហាសិបប្រាំមួយដុល្លារសហរដ្ឋអាមេរិក) និងចំនួន ១.៦៦៧.៧០០.០០០រៀល (មួយពាន់លានប្រាំមួយរយហុកសិបប្រាំពីរពាន់លានប្រាំពីររយពាន់រៀលគត់)(ដូចក្នុងឧបសម្ព័ន្ធ៣)។

**៧.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

**៧.៤.១-កម្មវិធីគាំទ្រដោយអង្គការសហប្រជាជាតិសម្រាប់កុមារ UNICEF**

-បានចុះពិនិត្យ និងរៀបចំទូទាត់បុរេប្រទានត្រីមាសទី៣ របស់គម្រោងលើកកម្ពស់វិស័យសេវាសង្គម នៅខេត្តរតនគិរី និងខេត្តក្រចេះ

-បានចូលរួមកិច្ចប្រជុំជាមួយតំណាងអង្គការយូនីសេហ្វស្តីពីការអនុវត្តកិច្ចព្រមព្រៀងឆ្នាំ២០២០

-បានរៀបចំកិច្ចប្រជុំពិភាក្សា លើសកម្មភាពសម្រាប់ដាក់បញ្ចូលផែនការសកម្មភាព២ឆ្នាំរំកិល «២០២០-២០២១»ជាមួយតំណាងអង្គការយូនីសេហ្វ

-បានរៀបចំលិខិតជូនដំណឹងទៅរដ្ឋបាលរាជធានី ខេត្ត ស្តីពីការគាំទ្រ និងកិច្ចសហការពីរដ្ឋបាលរាជធានីខេត្តក្នុងការចុះប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវ ស្តីពីការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំផែនការ និងថវិកានៅរដ្ឋបាលឃុំ សង្កាត់

-បានសហការចុះប្រមូលទិន្នន័យសម្រាប់ការសិក្សា ស្រាវជ្រាវ ស្តីពីការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំផែនការ និងថវិកានៅរដ្ឋបាលឃុំ សង្កាត់ នៅខេត្តក្រចេះ ខេត្តកណ្តាល និងរាជធានីភ្នំពេញ។

**៧.៤.២-គម្រោងសាងសង់អាគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP**

គិតត្រឹមខែមីនា ឆ្នាំ២០២០នេះ ការវិវឌ្ឍនៃដំណើរការការដ្ឋានសាងសង់អគាររដ្ឋបាលស្រុក និងឃុំ សង្កាត់ គិតជារួមបានប្រមាណ៥៧% ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានចាត់មន្ត្រី៖

-ចុះពិនិត្យតាមដានដំណើរការសាងសង់អគារសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ដំណាក់កាលទី១ និងទី២ ។ ទន្ទឹមនេះ គម្រោង ក៏បានចុះកិច្ចសាងសង់សម្រាប់កញ្ចប់លទ្ធកម្មរៀបចំកិច្ចសន្យាទី១១ នៃដំណាក់កាលទី៣ ផងដែរ។

**៧.៥-ការងារគម្រោងមូលនិធិ និងការគាំទ្រក្រុង ស្រុក ឃុំ សង្កាត់**

**៧.៥.១-គម្រោងក្រុង ស្រុក**

ការរៀបចំគម្រោងក្រុង ស្រុក ឆ្នាំ២០២០ មានចំនួន ២៥២គម្រោង ដែលក្នុងនោះ៖ គម្រោងមិនទាន់សិក្សាចំនួន ១៨៨គម្រោង (ស្មើនឹង៧៤,៦០%) គម្រោងកំពុងដំណើរការសិក្សាចំនួន ៤៥គម្រោង (ស្មើនឹង ១៧,៨៦%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន ១៩គម្រោង(ស្មើនឹង៧,៥៤%)។ សម្រាប់គម្រោងក្រុង ស្រុក ឆ្នាំ ២០១៩ មានចំនួន ៥៣៥គម្រោង ដែលក្នុងនោះ៖ គម្រោងមិនទាន់សិក្សាចំនួន ៣១គម្រោង (ស្មើនឹង៥,៨០%) គម្រោងកំពុងដំណើរការសិក្សាចំនួន ១៥គម្រោង(ស្មើនឹង ២,៨០%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន ៤៨៩គម្រោង (ស្មើនឹង៩១,៤០%) ហើយបានដេញថ្លៃរួចចំនួន ៤៨៤គម្រោង(ស្មើនឹង៩៨,៩៨%)នៃគម្រោងដែលបានបញ្ចប់ការសិក្សា។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងក្រុង ស្រុកឆ្នាំ២០១៩ មានចំនួន ៤៧៨កិច្ចសន្យា ក្នុងនោះរួមមាន៖ បញ្ចប់ការសាងសង់១០០% ចំនួន ៤២០កិច្ចសន្យា(ស្មើនឹង៨៧.៨៧%) អនុវត្តបានលើស៥០% ចំនួន ១៩កិច្ចសន្យា (ស្មើនឹង៣,៩៧%) អនុវត្តបានតិចជាង៥០%ចំនួន ២៤កិច្ចសន្យា(ស្មើនឹង៥,០២%) និងមិនទាន់បានអនុវត្តចំនួន ១៥កិច្ចសន្យា(ស្មើនឹង ៣,១៤%)។

**៧.៥.២-គម្រោងមូលនិធិឃុំ សង្កាត់**

ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២០ មានចំនួន ១.៤៧៩គម្រោង(ក្នុងនោះ កំពុងដំណើរការសិក្សាចំនួន **៥៥៦គម្រោង**(ស្មើនឹង៣៧,៥៩%) មិនទាន់ចាប់ផ្តើមសិក្សាចំនួន **៧៥៦គម្រោង**(ស្មើនឹង៥១,១២%) និងបានបញ្ចប់ការសិក្សាចំនួន **១៦៧គម្រោង**(ស្មើនឹង ១១,២៩%) ហើយគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **៦គម្រោង** (ស្មើនឹង ៣,៥៩%) បានដេញថ្លៃរួចរាល់។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិ ឃុំ សង្កាត់ឆ្នាំ២០២០ សរុបចំនួន **១កិច្ចសន្យា** ក្នុងនោះរួមមាន៖ ការអនុវត្តបានលើសពី៥០%ចំនួន **១កិច្ចសន្យា**(ស្មើនឹង ១០០%)។ ដោយឡែកការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៩ មានចំនួន **១.៨០២គម្រោង**(ក្នុងនោះ កំពុងសិក្សាចំនួន ០៩គម្រោង (ស្មើនឹង០,៥០%) បានបញ្ចប់ការសិក្សាចំនួន **១៧៩៣គម្រោង** (ស្មើនឹង៩៩,៥០%) ហើយគម្រោងចំនួន **១៧៦៧គម្រោង**(ស្មើនឹង ៩៨,៥៥%) បានដេញថ្លៃរួចរាល់។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំ សង្កាត់ ២០១៩សរុបចំនួន **១.៧៣៨កិច្ចសន្យា** ក្នុងនោះរួមមាន៖ ការអនុវត្តបានលើសពី៥០%ចំនួន**២២៧កិច្ចសន្យា**(ស្មើនឹង១៣,០៧%)ការអនុវត្តបានតិចជាង៥០%ចំនួន**១៨៩កិច្ចសន្យា** (ស្មើនឹង ១០,៨៧%) បញ្ចប់ការសាងសង់១០០% ចំនួន **១.១៣៦កិច្ចសន្យា** (ស្មើនឹង៦៥,៣៦%) និងមិនទាន់បានអនុវត្តចំនួន **១៨៦កិច្ចសន្យា** (ស្មើនឹង ១០,៧០%) ។

**៧.៦-ការផ្តល់សេវា និងការដោះស្រាយវិវាទនៅមូលដ្ឋាន**

**៧.៦.១-ការផ្ទេរមុខងារ និងធនធាន**

-ប្រមូល និងបូកសរុបរបាយការណ៍នៃការអនុវត្តមុខងារគ្រប់គ្រងមណ្ឌលថែទាំរដ្ឋ របស់រដ្ឋបាលរាជធានី ខេត្ត

-កែសម្រួលបញ្ចប់សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត

**៧.៦.២-ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយ**

**ក.ការផ្តល់សេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយ**

ក្នុងខែមីនា ឆ្នាំ២០២០នេះ អង្គភាពច្រកចេញចូលតែមួយទាំង២៥រាជធានី ខេត្តបានផ្តល់សេវារដ្ឋបាលសរុបចំនួន **៤៧.៤៤០សេវា** ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថាវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផ្តល់សេវាបានច្រើនជាងគេគឺចំនួន **១៨.១៥៥សេវា**(ស្មើនឹង **៣៨,២៧%**)បន្ទាប់មកវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន **៩.៧៥៨សេវា** (ស្មើនឹង**២០,៥៧%**) (**ដូចក្នុងឧបសម្ព័ន្ធ៤**)។ ជាមួយគ្នានេះដែរអង្គភាពច្រកចេញចូលតែមួយទាំង ២៥រាជធានី ខេត្តទទួលបានចំណូលសរុបចំនួន ៦.៥៤៩.៩០២.៩៨០រៀល (ស្មើនឹង១.៦៣៧.៤៧៥,៧៤៥ដុល្លារអាមេរិក) ក្នុងនោះបើប្រៀបធៀបចំណូលដែលទទួលបាននៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា វិស័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ទទួលបានចំណូលខ្ពស់ជាងគេគឺ ៥.២២១.៥២៣.៩៨០រៀល (ស្មើនឹង៧៩,៧២%) បន្ទាប់មកវិស័យការងាររដ្ឋបាលទទួលបានចំណូលចំនួន ៣៨៤.៣៩៨.៥០០រៀល(ស្មើនឹង ៥,៨៧%) (**ដូចក្នុងឧបសម្ព័ន្ធ៥**)។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាល បានអនុវត្តសកម្មភាពមួយចំនួន ដើម្បីគាំទ្រដល់អង្គភាពច្រកចេញចូលតែមួយដូចខាងក្រោម៖

-បានធ្វើលិខិតណែនាំទៅរដ្ឋបាលខេត្តតាកែវ ស្តីពីលទ្ធផលនៃការចុះពិនិត្យលើការគ្រប់គ្រង និងការបែងចែកចំណូលដែលបានមកពីការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយខេត្តតាកែវ

-បានចុះកិច្ចសន្យាជាមួយអ្នករៀបចំកម្មវិធីព័ត៌មានវិទ្យា ដើម្បីរៀបចំ និងដាក់ឱ្យដំណើរការកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

**ខ.ការផ្ដល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយ**

ក្នុងខែមីនា ឆ្នាំ២០២០នេះ ការិយាល័យច្រកចេញចូលតែមួយទាំង៨៣គោលដៅបានផ្ដល់សេវារដ្ឋបាលសរុបចំនួន ១៤៣.៩២៧សេវា បើប្រៀបធៀបចំនួនសេវាដែលបានផ្ដល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថាវិស័យនីត្យានុកូលកម្មបានផ្ដល់សេវាបានច្រើនជាងគេគឺចំនួន ៧៩.៦៧៨សេវា (ស្មើនឹង៥៥,៣៦%) បន្ទាប់មកវិស័យសាធារណការនិងដឹកជញ្ជូនចំនួន ៤៩.៤៣២សេវា (ស្មើនឹង ៣៤,៣៥%) រីឯវិស័យរ៉ែ និងថាមពលផ្ដល់សេវាតិចជាងគេគឺ ចំនួន ០១សេវា (ស្មើនឹង០,០០១%)(ដូចក្នុងឧបសម្ព័ន្ធ៦)។ រយៈពេលដូចគ្នានេះដែរការិយាល័យច្រកចេញចូលតែមួយទាំង៨៣គោលដៅទទួលបានប្រាក់ចំណូលសរុបចំនួន ១.២៧៦.៣០៨.៤៧០រៀល (ស្មើនឹង ៣១៩.០៧៧,១២ដុល្លារអាមេរិក) បើប្រៀបធៀបចំណូលដែលទទួលបានពីវិស័យទាំង១៤ ឃើញថា វិស័យសុរិយោដីមានចំណូលខ្ពស់ជាងគេគឺចំនួន ៦៥៤.៤២១.២០០រៀល (ស្មើនឹង ៥១,២៧%)បន្ទាប់មកវិស័យសំណង់ទទួលបានចំណូលចំនួន ២៨៦.១២៣.០០០រៀល(ស្មើនឹង២២,៤២%) រីឯវិស័យរ៉ែ និងថាមពលផ្ដល់ចំណូលបានតិចជាងគេគឺចំនួន៥០.០០០រៀល(ស្មើនឹង ០,០០៤%)(ដូចក្នុងឧបសម្ព័ន្ធ៧)។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាល បានអនុវត្តសកម្មភាពមួយចំនួនដើម្បីគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយដូចខាងក្រោម៖

-បានរៀបចំឯកសារទស្សនទាន និងបញ្ជីសំណួរ សម្រាប់ចុះសិក្សាការរៀបចំការិយាល័យច្រកចេញចូលតែមួយ ការកែសម្រួលតួនាទី ភារកិច្ច និងនីតិវិធីនៃការផ្ដល់សេវារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

-បានជូនដំណឹងទៅរដ្ឋបាលរាជធានី ខេត្ត ស្ដីពីការរៀបចំដាក់ឱ្យដំណើរការការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌគោលដៅថ្មីទាំង៣២។

**៧.៦.៣-ការដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

**ក).ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ក្នុងខែមីនា ឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តបានទទួលបណ្ដឹង សំណូមពរ ការទិតៀន ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធសរុបចំនួន **៧៧ករណី** ក្នុងនោះ បណ្ដឹងក្នុងសមត្ថកិច្ចចំនួន **១៤ករណី** (បញ្ចប់ការដោះស្រាយ ០៦ករណី កំពុងដោះស្រាយ ០៨ករណី) បណ្ដឹងក្រៅសមត្ថកិច្ចចំនួន **២៤ករណី** សំណូមពរចំនួន **២៤ករណី** ការសរសើរចំនួន **០១ករណី** និងការសាកសួរព័ត៌មានផ្សេងៗចំនួន **១៤ករណី**។ ចំពោះបណ្ដឹងក្នុងសមត្ថកិច្ចដែលនៅសល់ពីខែកន្លងមកមានចំនួន១០ករណី (បញ្ចប់ការដោះស្រាយចំនួន ០៣ករណី កំពុងដោះស្រាយចំនួន ០៧ករណី)។ ជាមួយគ្នានេះដែរ **អគ្គនាយកដ្ឋានរដ្ឋបាល** ក៏បានអនុវត្តកិច្ចការចាំបាច់មួយចំនួនដើម្បីគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តដូចខាងក្រោម៖

-បានធ្វើបច្ចុប្បន្នភាពអំពីចំនួនបុគ្គលិកបំពេញការងារ សម្ភារប្រើប្រាស់ និងការរៀបចំផែនការសកម្មភាព និងថវិការបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត សម្រាប់ឆ្នាំ២០២០

-បានគាំទ្រដំណើរការបោះឆ្នោតជ្រើសរើសអនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្តកំពត និងខេត្តកោះកុង។

**ខ).ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ**

ក្នុងខែមីនា ឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌបានទទួលបណ្ដឹង សំណូមពរ ការទិតៀន ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធសរុបចំនួន **៧៩៧ករណី** ក្នុងនោះបណ្ដឹងក្នុងសមត្ថកិច្ច **១៤ករណី** (បញ្ចប់ការដោះស្រាយ ០៩ករណី កំពុងដោះស្រាយ ០៥ករណី)និងបណ្ដឹងក្រៅសមត្ថកិច្ចចំនួន **១៦ករណី** ការសរសើរចំនួន **៣៦ករណី** សំណូមពរចំនួន **៧៩ករណី** ការសាកសួរព័ត៌មានផ្សេងៗចំនួន **៦៥២ករណី**។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានអនុវត្តកិច្ចការចាំបាច់មួយចំនួនដើម្បីគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌដូចខាងក្រោម៖

-បានគាំទ្រដំណើរការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ គោលដៅថ្មីចំនួន៣២គោលដៅឆ្នាំ២០១៩

-បានរៀបចំសំណើសុំប្រកាសទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋស្រុកម៉ាឡៃ និងស្រុកបន្ទាយស្រី

-បានដាក់ចេញប្រកាសទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ចំនួន៣គោលដៅគឺៈ ក្រុងខេមរភូមិន្ទ ស្រុកអង្គរជ័យ និងស្រុកគិរីវង់

-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ដល់ប្រធាន និងជំនួយការការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌគោលដៅថ្មីចំនួន ៣២គោលដៅ និងប្រធាន និងជំនួយការការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌគោលដៅចាស់មួយចំនួនសរុប ៧៥នាក់ ចាប់ពីថ្ងៃទី០៤ដល់០៦ ខែមីនា ឆ្នាំ២០២០ នៅខេត្តសៀមរាប។

**៨-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ក្នុងខែមីនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានធ្វើលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ន អង្គភាពនានា និងរដ្ឋបាលរាជធានី ខេត្ត ដូចខាងក្រោមៈ

**-រដ្ឋបាលខេត្តសៀមរាប** ករណីអនុញ្ញាតជាគោលការណ៍ឱ្យៈ

- ដឹកនាំប្រតិភូមន្ត្រីរាជការរដ្ឋបាលខេត្តសៀមរាបទៅទស្សនកិច្ចនៅខេត្តកោះកុង
- រដ្ឋបាលខេត្តព្រះសីហនុដឹកនាំគណៈប្រតិភូនារីចំនួន១២០រូប ទៅទស្សនៈកិច្ចនៅខេត្តសៀមរាប។

**-ក្រសួងបរិស្ថាន** ករណីស្នើសុំចាត់មន្ត្រីបច្ចេកទេស ០១រូប ចូលរួមជាសមាជិកក្រុមការងារអន្តរក្រសួងចុះកំណត់ស្ថានីយ៍បុរាណនៅខេត្តតាកែវ ដើម្បីរក្សាទុកជាតំបន់អភិរក្សបេតិកភ័ណ្ឌ

**-អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល** ករណីសំណើសុំអនុញ្ញាតបន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការិយាល័យ ព័ត៌មានឈ្លាសវៃ និងអភិបាលកិច្ចល្អក្នុងវិស័យព័ត៌មាន"

**-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ** ករណីៈ

- គណនីហ្វេសប៊ុកឈ្មោះ គន្ធា សម័យតេជោ ផ្ញើសារសម្លេងចូលប្រអប់សារហ្វេសប៊ុករបស់ សម្តេចក្រឡាហោមពាក់ព័ន្ធនឹងរឿងស្ត្រីម្នាក់មានជីវភាពខ្វះខាតស្នើសុំឧបត្ថម្ភជាអង្ករ និងម្សៅទឹកដោះគោសម្រាប់កូន។
- គណនីហ្វេសប៊ុកឈ្មោះ To Ratanak បង្ហោះសារចូលក្នុងគេហទំព័រហ្វេសប៊ុករបស់សម្តេចក្រឡាហោមពាក់ព័ន្ធនឹងករណីចៅសង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង មិនព្រមចុះហត្ថលេខាលើលិខិតលក់-ទិញដី។

**-អគ្គនាយកដ្ឋានគស្តុការ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ** ករណីៈ

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចាត់តំណាងចូលរួមក្នុងគណៈកម្មការអន្តរក្រសួង ចុះពិនិត្យសិក្សា និងវាយតម្លៃដីឯកជនរបស់រដ្ឋមួយកន្លែងមានទំហំ ៨.៥២៨ម៉ែត្រការ៉េ ស្ថិតនៅភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដែលលោកឧកញ៉ា អាន ម៉ានី ស្នើសុំគោលការណ៍ទិញ
- សំណើសុំជម្រះដី ០១ទីតាំង មានទំហំ ៥៥៣ម៉ែត្រការ៉េ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

**-រដ្ឋបាលរាជធានី ខេត្តករណីៈ**

- ក្រសួងបរិស្ថាន ស្នើសុំធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់សាធារណៈ
- មូលនិធិគន្ធបុប្ផា ស្នើសុំធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចស្តីពី "ក្រមសីលធម៌សម្រាប់បុគ្គលកៀរគរ និងប្រមូល ឬការទទួលវិភាគទានសប្បុរសធម៌នៃមូលនិធិគន្ធបុប្ផាកម្ពុជា"

**-រដ្ឋបាលខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងរដ្ឋបាលខេត្តព្រះសីហនុ** ករណីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាស្នើសុំសម្របសម្រួលការចុះបំពេញបេសកកម្មរបស់គណៈកម្មការទី១ ទី៣ ទី៤ ទី៦ និងទី៩ នៃព្រឹទ្ធសភា

**-រដ្ឋបាលខេត្តស្ទឹងត្រែង ក្រចេះ រតនគិរី និងរដ្ឋបាលខេត្តព្រះវិហារ** ករណីអង្គការកម្មវិធីផ្លាស់ប្តូរបទពិសោធន៍អនុផលព្រៃឈើកម្ពុជា ស្នើសុំអញ្ជើញអភិបាល ឬអភិបាលរងទទួលបន្ទុកផ្នែកធនធានធម្មជាតិ និងបរិស្ថាន ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី "ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ"

-រដ្ឋបាលខេត្តស្ទឹងត្រែង ករណីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ស្នើសុំឱ្យរដ្ឋបាលខេត្តស្ទឹងត្រែងជួយសហការក្នុងការរៀបចំពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផលនានាក្នុងវត្តពោធិជ័យ(វត្តសៀមប៉ាង) ស្ថិតនៅភូមិសៀមប៉ាង ឃុំសេកុង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង

-រដ្ឋបាលខេត្តស្វាយរៀង ករណីអគ្គលេខាធិការដ្ឋានរដ្ឋសភា ស្នើសុំសម្របសម្រួលការចុះបំពេញបេសកកម្មរបស់គណៈកម្មការទី៣ នៃរដ្ឋសភា

-វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ករណីៈ

- ស្នើសុំការអនុញ្ញាតចុះធ្វើការអង្កេតស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ផ្តោតសំខាន់ទៅលើវិស័យកសិកម្ម និងការកាត់បន្ថយភាពក្រីក្រ និងកំណើនសម្រាប់គ្រប់គ្នានៅប្រទេសកម្ពុជា។
- ស្នើសុំការអនុញ្ញាតចុះធ្វើអង្កេតស្តីពី សេចក្តីជឿជាក់លើការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចផ្តោតសំខាន់ទៅលើការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តក្នុងគ្រួសារ និងទីផ្សារការងារ។

### ៩.ការងារតាមវិស័យផ្សេងៗ

#### ៩.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងប័ណ្ណព្រំដែន

**ក.ការងារច្រកទ្វារព្រំដែន**

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារព្រំដែនសរុបចំនួន ៨២ច្រក រួមមាន ច្រកទ្វារកំពង់ផែអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារព្រំដែនអន្តរជាតិចំនួន ២៦ច្រក ច្រកទ្វារព្រំដែនទ្វេភាគីចំនួន ១៤ច្រក ច្រកទ្វារតំបន់ព្រំដែនចំនួន ២៦ច្រក និងច្រកទ្វារកំពង់ផែសមុទ្រចំនួន ១០ច្រក។ ជាមួយគ្នានេះផងដែរ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំលិខិតជម្រាបជូនទៅៈ

-រដ្ឋបាលខេត្តព្រៃវែង ករណីភាគីវៀតណាមដំឡើងកម្រិតច្រកទ្វារតំបន់ព្រំដែនតឹនណាម(ខេត្តតៃនីញ) ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ(ខេត្តព្រៃវែង)ទៅជាច្រកទ្វារព្រំដែនអន្តរជាតិ។

-រដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម ករណីសុំផ្តល់របាយណ៍ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម។

**ខ.ការងារប័ណ្ណព្រំដែន**

ចាប់តាំងពីដាក់ឱ្យដំណើការប្រើប្រាស់ជាផ្លូវការនូវប័ណ្ណព្រំដែនកម្ពុជា-ថៃនិងប័ណ្ណព្រំដែនកម្ពុជា-ឡាវ រហូតមកដល់បច្ចុប្បន្ន អគ្គនាយកដ្ឋានរដ្ឋបាលបានធ្វើការតាមដាន ត្រួតពិនិត្យ និងផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងសម្ភារៈជូនទៅរដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ និងប្រទេសឡាវជាប្រចាំ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ដំណើការផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋឱ្យប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែង អគ្គនាយកដ្ឋានរដ្ឋបាលក៏បានធ្វើលិខិតជម្រាបជូនរដ្ឋបាលខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តកោះកុង ករណីស្តីពីការពង្រឹងបន្ថែមនូវការងារផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ។

គិតចាប់ពីថ្ងៃទី១៩ខែកុម្ភៈ ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ អគ្គនាយកដ្ឋានរដ្ឋបាលបានផ្តល់ប័ណ្ណព្រំដែនជូនរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ សរុបចំនួន ៨.០០០ប័ណ្ណ (ក្នុងនោះ ខេត្តបាត់ដំបង ៥.០០០ប័ណ្ណ និងខេត្តប៉ៃលិន ៣.០០០ប័ណ្ណ) ។ ក្នុងខែមីនា ឆ្នាំ២០២០នេះ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃបានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋប្រើប្រាស់ជាផ្លូវការសរុបចំនួន៩.៥៨៥ប័ណ្ណ (ក្នុងនោះខេត្តបាត់ដំបង ៤.២៩៥ប័ណ្ណ ខេត្តបន្ទាយមានជ័យ ២.១១៩ ប័ណ្ណ ខេត្តឧត្តរមានជ័យ ១.២០៣ប័ណ្ណ ខេត្តប៉ៃលិន ១.៧០២ប័ណ្ណ និងខេត្តកោះកុងចំនួន២៦៦ប័ណ្ណ) និងរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ បានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋចំនួន ០២ប័ណ្ណ។

#### ៩.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីបង្កើនទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាពជាមិត្តភាព និងសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានាជាមិត្ត ក្រសួងមហាផ្ទៃបានអនុញ្ញាតជាគោលការណ៍ឱ្យរដ្ឋបាលរាជធានីខេត្តចុះហត្ថលេខាលើអនុស្សរណៈ (MOU) ផ្លាស់ប្តូរទស្សនៈកិច្ចសិក្សា និងកិច្ចសហប្រតិបត្តិការដូចខាងក្រោមៈ

-រដ្ឋបាលខេត្តកោះកុង ករណីសុំគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលខេត្តកោះកុងចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្កើតចំណងទំនាក់ទំនងមិត្តភាពរវាងខេត្តកោះកុង និងខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន។

-រដ្ឋបាលខេត្តព្រះសីហនុ ករណីអនុញ្ញាតជាគោលការណ៍ឱ្យ៖

- នាវាផ្ទាំសមុទ្រឥណ្ឌាចូលចត និងធ្វើទស្សនកិច្ចនៅកំពង់ផែស្វ័យខេត្តព្រះសីហនុ។
- ដឹកនាំប្រតិភូខេត្តព្រះសីហនុទៅចូលរួមបំពេញទស្សនកិច្ចសិក្សា ស្តីពីការគ្រប់គ្រងសំណល់រឹង នៅចក្រភពអង់គ្លេស។

### ៩.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ

ក្នុងខែមីនាឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច លើសំណើសុំផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៩ចំនួន ៣១គម្រោងរបស់រដ្ឋបាលរាជធានី ខេត្ត ចំនួន០៤រួមមាន៖ រាជធានីភ្នំពេញ(១៨គម្រោង) ខេត្តត្បូងឃ្មុំ(៧គម្រោង) ខេត្តសៀមរាម(១គម្រោង) និងខេត្តកណ្តាល(៥គម្រោង) មានទឹកប្រាក់សរុបចំនួន ១៤៥.១១១.៣១៤.៧០០ រៀល (មួយរយសែសិបប្រាំបីលានមួយរយដប់មួយលានបីរយដប់បួនពាន់ប្រាំពីររយរៀលគត់) និងគម្រោងអភិវឌ្ឍ ឆ្នាំ២០២០ ចំនួន ២៦គម្រោងរបស់រដ្ឋបាលខេត្តចំនួន ០៤រួមមាន៖ខេត្តស្វាយរៀង(៣ម្រោង) ខេត្តព្រះសីហនុ(១២ម្រោង) ខេត្តកណ្តាល(១គម្រោង) និងខេត្តកំពង់ចាម(១០គម្រោង)មានទឹកប្រាក់សរុបចំនួន២៥.៥៦០.១២៨.០០០រៀល (ម្ភៃប្រាំបីលានប្រាំរយហុកសិបលានមួយរយម្ភៃប្រាំបីពាន់រៀលគត់)(ដូចក្នុងឧបសម្ព័ន្ធ៨)។ ទន្ទឹមនោះដែរក្រសួងមហាផ្ទៃក៏បានសម្រេចផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍឆ្នាំ២០១៩ចំនួន ៩៨គម្រោង របស់រដ្ឋបាលរាជធានីខេត្តចំនួន ០៧ រួមមាន៖ រាជធានីភ្នំពេញ(៦០គម្រោង) ខេត្តកំពត(១គម្រោង) ខេត្តព្រះវិហារ(៦គម្រោង) ខេត្តសៀមរាប(២១គម្រោង) ខេត្តបន្ទាយមានជ័យ(១គម្រោង) ខេត្តឧត្តរមានជ័យ(៥គម្រោង) និងខេត្តព្រះសីហនុ(៤គម្រោង) មានទឹកប្រាក់សរុបចំនួន ៣៣០.៥៣៤.២៣៥.៩៦០រៀល (បីរយសាមសិបបីលានប្រាំរយសាមសិបបួនលានពីររយសាមសិបប្រាំពាន់ប្រាំបួនរយហុកសិបរៀលគត់)(ដូចក្នុងឧបសម្ព័ន្ធ៩)។

ទន្ទឹមនោះ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានរៀបចំលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ននានា អង្គភាពចំណុះ និងរដ្ឋបាលខេត្តមួយចំនួនដូចខាងក្រោម៖

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ករណី៖

- រដ្ឋបាលខេត្តព្រៃវែង ស្នើសុំជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋនូវរថយន្តចំនួន ០២គ្រឿង និងទីតាំងដីចាក់សំរាម ០១កន្លែង របស់រដ្ឋបាលខេត្តព្រៃវែង។
- រដ្ឋបាលខេត្តបន្ទាយមានជ័យ ស្នើសុំគោលការណ៍ឯកភាពលើការវាយតម្លៃ នៃការដោះដូរទីតាំងដី និងអគាររបស់មណ្ឌលសុខភាពប៉ោយប៉ែត ១ ស្ថិតនៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលរាជធានីភ្នំពេញ ករណី៖

- សំណើសុំសាងសង់អគារស្ថានីយ៍សាឡាងនៅទីតាំងកំពង់ចម្លងភ្នំពេញ-អរិយក្សត្រស្ថិតនៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ជាថ្នូរនឹងការទទួលបានសិទ្ធិវិនិយោគជាមួយរដ្ឋបាលរាជធានីភ្នំពេញក្នុងការធ្វើអាជីវកម្មជាភោជនីយដ្ឋាន និងហាងលក់ទំនិញនៅក្នុងអគារស្ថានីយ៍សាឡាង។
- សំណើសុំជួលរយៈពេលវែងនូវដីទំហំ ៣.០០០ម៉ែត្រការ៉េ ជាប់នឹងគល់ស្ពានកោះពេជ្រត្រើយខាងលិចស្ថិតនៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដើម្បីសាងសង់អគារពាណិជ្ជកម្មកម្ពស់ ៦៥ជាន់ និងចំណតរថយន្តក្រោមដី។
- សំណើសុំប្តូរទីតាំងមូលដ្ឋានកងរាជអាវុធហត្ថខណ្ឌដូនពេញ ទីតាំងប៉ុស្តិ៍នគរបាលសង្កាត់ចតុមុខ និងទីតាំងបន្ទប់ទឹកសាធារណៈ ស្ថិតនៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទៅកាន់ទីតាំងថ្មី និងស្នើសុំធ្វើប័ណ្ណកម្មសិទ្ធិនូវដីចំនួន ០៣ទីតាំង ក្នុងរាជធានីភ្នំពេញ។

-រដ្ឋបាលខេត្តបាត់ដំបង ករណីសំណើសុំរៀបចំអនុវត្តគម្រោងជីសម្បទានសង្គមកិច្ចសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋក្រីក្រដែលរងផលប៉ះពាល់ដោយការបាក់ស្រុតច្រាំងស្ទឹងសង្កែនៅក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង។ បានពិនិត្យនិងលើកយោបល់ជូនថ្នាក់ដឹកនាំស្តីពីសំណើសុំផ្តល់អនុលោមភាពផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង ស្វាយរៀង និងខេត្តបាត់ដំបង។

-បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំលើសំណើសុំផ្តល់អនុលោមភាពផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ (២០២០-២០២៤) របស់រដ្ឋបាលខេត្តកំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ ស្វាយរៀង និងខេត្តបាត់ដំបង ក្នុងនោះថ្នាក់ដឹកនាំបានសម្រេចផ្តល់អនុលោមភាពលើផែនការអភិវឌ្ឍន៍របស់រដ្ឋបាលខេត្តចំនួន១គឺ ផែនការអភិវឌ្ឍរបស់រដ្ឋបាលខេត្តកំពង់ចាម។

### ៩.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៩.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

គិតមកដល់បច្ចុប្បន្នសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជី នៅក្រសួងមហាផ្ទៃសរុបចំនួន ៥.៦២៩(ក្នុងនោះសមាគមចំនួន ២.២៩២ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣.៣៣៧) និងសហគមន៍ជនជាតិដើមភាគតិចចំនួន១៤២ (**ដូចក្នុងឧបសម្ព័ន្ធ១០**)។ ក្នុងខែមីនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានសម្រេចចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២២(ក្នុងនោះសមាគម១៤ អង្គការមិនមែនរដ្ឋាភិបាល៧ និងសមាគមន៍ជនជាតិដើមភាគតិចចំនួន១) ព្រមទាំងបានសម្រេចលុបឈ្មោះចេញពីបញ្ជីអង្គការមិនមែនរដ្ឋាភិបាលតាមការស្នើសុំសរុបចំនួន៣ (**ដូចក្នុងឧបសម្ព័ន្ធ១០**)។ ជាមួយគ្នានេះផងដែរ ក៏បានបញ្ចូលទិន្នន័យស្តេនសំណុំឯកសារពាក់ព័ន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៤៣ច្បាប់ ក្នុងនោះសមាគមចំនួន ៤០ច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣ច្បាប់។

ទន្ទឹមនេះ ក៏បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេចពាក់ព័ន្ធនឹងការងារនានាដូចជាការសុំចុះឈ្មោះក្នុងបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល ការសុំទទួលស្គាល់ប្រធាន ការសុំផ្លាស់ប្តូរសមាសភាពថ្មី នៃរចនាសម្ព័ន្ធ ការសុំធ្វើវិសោធនកម្មលក្ខន្តិកៈ ការសុំបើកទីស្នាក់ការសាខា ការសុំប្តូរឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការលុបឈ្មោះ ការផ្អាកសកម្មភាពបណ្តោះអាសន្នចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

#### ៩.៤.២-ការងារគណបក្សនយោបាយ

គិតមកដល់បច្ចុប្បន្នគណបក្សនយោបាយមានចំនួនសរុប **៤៦គណបក្ស** ក្នុងនោះគណបក្សដែលបានចុះបញ្ជីមានចំនួន ៤៣គណបក្ស និងគណបក្សដែលបានបង្កើតមានចំនួន ០៣គណបក្ស (**ដូចក្នុងឧបសម្ព័ន្ធ១០**)។ ជាមួយនេះបានជូនដំណឹងចំពោះគណបក្សមហាសាមគ្គីជាតិខ្មែរ ដើម្បីរំលឹកក្នុងការបំពេញកាតព្វកិច្ចក្នុងការបង់ប្រាក់ផាកពិន័យ និងផាកពិន័យប្រាក់មួយទ្វេជាពីរ ព្រមទាំងផ្អាកសកម្មភាពជាបណ្តោះអាសន្នក្នុងរយៈពេលមួយឆ្នាំចំពោះគណបក្សវត្តតខេមរៈមហានគរ ។ទន្ទឹមនេះក៏បានធ្វើការរំលឹកដល់គណបក្សនយោបាយចំនួន ៦(ប្រាំមួយ)ឱ្យបំពេញលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីគណបក្សនយោបាយ។

## II-បញ្ហាប្រឈម និងសំណូមពរ

ទន្ទឹមនឹងការសម្រេចលទ្ធផលដូចខាងលើ ក្នុងការបំពេញភារកិច្ចកន្លងមក អគ្គនាយកដ្ឋានរដ្ឋបាលបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

-មិនទាន់បានដាក់ចេញគំរូពាក្យស្នើសុំ និងគំរូអាជ្ញាប័ណ្ណស្តង់ដាររួមសម្រាប់ការផ្តល់សេវារដ្ឋបាល នៅអង្គភាពច្រកចេញចូលតែមួយ

-ការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យមួយចំនួនដល់ការិយាល័យច្រកចេញចូលតែមួយ នៅមានទំហំតូចមិនសក្តិសមនឹងស្ថានភាពបច្ចុប្បន្នរបស់ក្រុង ស្រុក ខណ្ឌទិន្នន័យផ្ទុកក្នុងប្រព័ន្ធMISកាន់តែច្រើនទៅៗធ្វើឱ្យប្រព័ន្ធMISដំណើរការយឺតពិបាកក្នុងផលិតរបាយការណ៍ចេញ

-ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តមួយចំនួនពុំទាន់បានតែងតាំងបុគ្គលិកសម្រាប់បំពេញការងារ ឬសម្ភារពុំទាន់មានគ្រប់គ្រាន់ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តមួយចំនួនទៀតមានទីកន្លែងបំពេញការងារតូចចង្អៀតនៅឡើយ

-ការបញ្ជូនឯកសារពីក្រសួងមហាផ្ទៃទៅកាន់រដ្ឋបាលរាជធានី ខេត្ត និងការបញ្ជូនឯកសារពីរដ្ឋបាលរាជធានី ខេត្តមកក្រសួងមហាផ្ទៃនៅតែមានភាពយឺតយ៉ាវ

-ការផ្គត់ផ្គង់សម្ភារការិយាល័យដូចជាក្រដាសទឹកថ្នាំ ម៉ាស៊ីនថតចម្លងដើម្បីឆ្លើយតបសំណូមពរការងារមិនទាន់បានគ្រប់គ្រាន់ហើយការបើកសម្ភារៈពុំសូវមានគុណភាព

-ការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មសម្រាប់មន្ត្រីចុះបំពេញការងារនៅតាមខេត្ត មន្ត្រីរាជការត្រូវចំណាយថវិកាផ្ទាល់ខ្លួនជាមុនហើយបន្ទាប់ពីបញ្ចប់បេសកកម្មការបើកផ្តល់មានភាពយឺតយ៉ាវ

-មន្ត្រីមិនទាន់មានជំនាញគ្រប់គ្រាន់ក្នុងការសរសេរព័ត៌មាន និងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ទាមទារពេលវេលាហាត់រៀនបន្ថែម

ដើម្បីជំរុញការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកទឹកចិត្តមន្ត្រី ក្នុងការបំពេញការងារអគ្គនាយកដ្ឋានរដ្ឋបាល សំណូមពរដូចខាងក្រោម៖

-ពន្លឿនការកែសម្រួលទម្រង់បែបបទលក្ខខណ្ឌភ្ជាប់ការផ្តល់សេវាជាស្តង់ដាររួម

-បង្កើនទំហំប្រតិភូកម្មលើប្រភេទសេវាដែលស្ថិតក្នុងសមត្ថកិច្ចក្រុង ស្រុក ខណ្ឌ

-ផ្គត់ផ្គង់សម្ភារការិយាល័យឱ្យបានសមស្រប និងទាន់ពេលវេលាដើម្បីធានាឆ្លើយតបសំណូមពរការងារ

-ផ្តល់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មឱ្យបានលឿនជាងមុនបន្តិចបន្ទាប់ពីចុះបំពេញបេសកកម្ម។

## III-ទិសដៅការងារបន្ត

ដើម្បីជំរុញការអនុវត្តការងារឱ្យបានល្អប្រសើរ និងតាមផែនការដែលបានគ្រោងទុក អគ្គនាយកដ្ឋានរដ្ឋបាលបានដាក់ចេញនូវទិសដៅការងារបន្តសម្រាប់ខែមេសាឆ្នាំ២០២០ ដូចខាងក្រោម៖

### ១-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

#### ១.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុងដែលកំពុងរៀបចំ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ ការកែសម្រួល និងការកំណត់ឈ្មោះរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ

-សេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពីការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីការវាយតម្លៃជ្រើសរើសការិយាល័យច្រកចេញចូលតែមួយដែលមានស្នាដៃល្អនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ទីប្រជុំជន

-សេចក្តីព្រាងសៀវភៅណែនាំស្តីពី "កិច្ចការរដ្ឋបាល"សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

**១.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលរាជធានី ខេត្ត

-សេចក្តីព្រាងរៀបចំកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងរៀបចំកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤៣ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិកាវង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីនីតិវិធី នៃការចុះបញ្ជីសិប្បកម្មដែលមានដើមទុនសមមូលលើសពី៨០លារៀលដល់២០០.០០០.០០០រៀល និងគ្មានហានិភ័យ

-សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាល ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មរបស់DMF

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩-២០៣០។

**២-ការងារបុគ្គលិក**

**២.១-ការងារក្របខ័ណ្ឌ**

-បន្តរៀបចំបែបបទប្រឡងជ្រើសរើស សិស្ស និស្សិតឱ្យចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការមហាផ្ទៃ ក្នុងផែនការក្របខណ្ឌឆ្នាំ២០២០

-បន្តរៀបចំបែបបទសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ និងតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០២០

-បន្តរៀបចំបែបបទសុំដំឡើងឋានន្តរស័ក្តិ ជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទស្នើសុំផ្ទេរក្របខ័ណ្ឌពីមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ទៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗ និងពីក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ដើម្បីទៅបំពេញការងារក្នុងមុខតំណែងថ្មី និងអនុញ្ញាតឲ្យមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌដើមវិញ

-បន្តរៀបចំបែបបទដើម្បីតាំងស៊ប់ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីសុំពិនិត្យនីត្យានុកូលភាពលើប្រកាសតែងតាំង និងប្រគល់ភារកិច្ច ដើម្បីស្នើសុំផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទផ្តល់ទិដ្ឋាការលើសលាកបត្រជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**២.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល**

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីរាជការដែលទទួលមរណភាពនិងមន្ត្រីរាជការដែលសុំលាឈប់ពីការងារ

-បន្តរៀបចំការផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតអនុញ្ញាត ឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញ បន្ទាប់ពីសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីដែលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយហួសកាលកំណត់

-បន្តរៀបចំសំណុំលិខិតអនុញ្ញាតឈប់សម្រាកលំហែមាតុភាព

-បន្តរៀបចំសំណុំបែបបទផ្ទេរកូនកំព្រា និងសុំប្រាក់ធានារ៉ាប់រងសង្គម

-បន្តពិនិត្យផ្ទៀងផ្ទាត់សលាកបត្រមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារដែលដល់អាយុត្រូវចូលនិវត្តន៍ ឆ្នាំ២០២០

-បន្តពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រឿងឥស្សរិយយសមេដាយការងារ និងប័ណ្ណសរសើ ជូនមន្ត្រីរាជការស៊ីវិល។

**២.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

-បន្តរៀបចំផ្លាស់ប្តូរកន្លែងធ្វើការ រៀបចំដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិរយៈពេល០៣ខែ សម្រាប់មន្ត្រីរាជការស៊ីវិល និងដាក់ទណ្ឌកម្មខាងវិន័យសម្រាប់មន្ត្រីពន្ធនាគារ

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាពសម្រាប់ខែបន្ទាប់របស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាព និងតែងតាំងទីប្រឹក្សា ជំនួយការក្រសួងមហាផ្ទៃ និងទីប្រឹក្សា ជំនួយការ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរៀបចំស្នើសុំប្រាក់បៀវត្សទីប្រឹក្សា ជំនួយការ

-បន្តរៀបចំការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ

-បន្តរៀបចំក្រុមការងារពិពណ៌នាមុខតំណែងមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-បន្តរៀបចំការផ្អាកការងារ ដោយផ្អាកបៀវត្ស។

**២.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការចុះពង្រឹងរបៀបរបបការងារ និងការគ្រប់គ្រងមន្ត្រីរាជការ នៅតាមសាលារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

-ពិនិត្យ និងសិក្សាលើសំណើសុំកែសម្រួលរចនាសម្ព័ន្ធទីចាត់ការ អង្គភាព និងការិយាល័យនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តពិនិត្យ និងលើកយោបល់ ដើម្បីស្នើសុំការសម្រេចលើការតែងតាំងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវដល់អាណត្តិ ០៤ឆ្នាំ(និង០៨ឆ្នាំ)របស់ខ្លួន

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បន្តសហការ និងសម្របសម្រួលជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយលើការងារប្រកាសទ្រព្យសម្បត្តិ និង បំណុលសម្រាប់ឆ្នាំ២០២០។

**២.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តយកចិត្តទុកដាក់ពិនិត្យលើកយោបល់ទាក់ទងការផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានទាន់ពេលវេលា

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

**២.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

-សិក្សា និងរៀបចំភ្ជាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រប់ការិយាល័យដែលពាក់ព័ន្ធចំណុះនាយកដ្ឋានបុគ្គលិក

-បន្តសហការជាមួយក្រុមហ៊ុនក្នុងការរៀបចំប្រព័ន្ធឲ្យមានភាពល្អប្រសើរជាងមុន

-បន្តធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាបន្តបន្ទាប់
-បន្តសហការជាមួយមន្ត្រីបង្គោល នៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីប្រមូលប្រវត្តិរូបមន្ត្រីកម្មសិក្សាក្របខ័ណ្ឌថ្មី ឆ្នាំ២០២០ និង មន្ត្រីដែលទើបផ្ទេរចូលថ្មី រួមទាំងឯកសារមន្ត្រីរាជការ ដែលមានការប្រែប្រួលស្ថានភាពជាបន្តបន្ទាប់
-កំពុងធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការសម្រាប់ខេត្តព្រះសីហនុ
-ធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការដូចជាការផ្លាស់ប្តូរទីកន្លែងធ្វើការ ការតែងតាំង ការប្រែប្រួលថ្នាក់ ឋានន្តរស័ក្តិ ការលុបឈ្មោះ ការចូលនិវត្តន៍...។ល។ទៅក្នុងប្រព័ន្ធ។

**៣-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៣.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់រាជធានី ខេត្ត ស្របតាមផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលជំនាញសម្រាប់ក្រុមគោលដៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
-បន្តរៀបចំឯកសារបណ្តុះបណ្តាលសម្រាប់ស្មៀនឃុំ សង្កាត់
-បន្តចងក្រងទិន្នន័យអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ
-រៀបចំកិច្ចការចាំបាច់នានាសម្រាប់ដាក់ឱ្យដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA)
-សិក្សាស្រាវជ្រាវ និងចងក្រងឯកសារអភិបាលកិច្ចមូលដ្ឋាន។

**៣.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

-បន្តរៀបចំបែបបទដើម្បីបញ្ជូនមន្ត្រីទៅចូលរួមសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅក្រៅប្រទេស
-បន្តសហការជាមួយដៃគូ ដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហការសម្រាប់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ
-បន្តរៀបចំបែបបទ ដើម្បីស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការតាមការស្នើសុំពីមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៣.៣-ការងារផ្សព្វផ្សាយ និងព័ត៌មាន**

-បន្តធ្វើបច្ចុប្បន្នភាពនិងបញ្ចូលអត្ថបទក្នុងគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល
-បន្តស្រាវជ្រាវ និងសរសេរអត្ថបទដើម្បីបញ្ចូលទៅក្នុងព្រឹត្តិបត្រ «រមែជ្ឈការ និងវិសហមជ្ឈការ» ក្រសួងមហាផ្ទៃលេខ ០៤។

**៤-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ**

**៤.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍**

ដើម្បីគាំទ្រដល់ការបំពេញតួនាទីភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច និងបន្តអនុវត្តលើកិច្ចការមួយចំនួនដូចខាងក្រោម៖
-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណី៖
•ឈ្មោះ អ៊ូ ប៊ុនណារិទ្ធ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តបន្ទាយមានជ័យ ដើម្បីធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុមួយកន្លែង ស្ថិតនៅភូមិអណ្តូងថ្មចាស់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
•ឈ្មោះ ប៉ូច ប៉េង ស្នើសុំជួយអន្តរាគមន៍ដោះស្រាយរកយុត្តិធម៌ ករណីទំនាស់ដីធ្លីទំហំ ៣៥ហិកតា មានទីតាំងនៅខាងជើងភូមិព្រៃសង្ហារ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ និងសុំបដិសេធលិខិតលេខ ១៧១/១៩ របក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ
-រដ្ឋបាលខេត្តតាកែវ ករណីឈ្មោះ ឥន្ទ គា, ឡូត ស្រីពៅ, តាំង ថា, តាំង សៀន, សុំ សុខលី, អៀម នាង, អ៊ូ ប៊ុណ្ណា, ហាក់ ហេង, ថាវ សុគន្ធ, អូន ថា, សែត ខុន និងឈ្មោះ ដួង សុខា ស្នើសុំចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋចំនួន ១២គ្រួសារ ស្ថិតនៅភូមិ២ សង្កាត់កោក្នុង ក្រុងដូនកែវ ខេត្តតាកែវ

-រដ្ឋបាលខេត្តកំពង់ស្ពឺ ករណីឈ្មោះ ហេង វណ្ណៈ ស្នើសុំប្តឹងឈ្មោះ ម៉ី ខេត ជាមេឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងបក្ខពួកលើករណីប្រើអំណាច ឃុបឃិតគ្នាលក់ដីរបស់គាត់ឱ្យអ្នកផ្សេងស្ថិតនៅភូមិរលួស ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

-រដ្ឋបាលខេត្តព្រះសីហនុ ករណីឈ្មោះ ហុក ឡេង ស្នើសុំចាត់វិធានការលើជនខិលខូចឃុបឃិតគ្នាធ្វើប្លង់ និងរំលោភយកដីរបស់គាត់ចំនួន ០៤ទីតាំង ស្ថិតនៅសង្កាត់លេខ២ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ឃុំរាម និងឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

-រដ្ឋបាលខេត្តមណ្ឌលគិរី ករណីស្នើសុំពិនិត្យសម្រេចលើការកំណត់និមិត្តសញ្ញារបស់រដ្ឋបាលខេត្តមណ្ឌលគិរី សម្រាប់ប្រើប្រាស់ជាផ្លូវការ។

-រដ្ឋបាលខេត្តរតនគិរី ករណីស្នើសុំពិនិត្យសម្រេចលើការកំណត់និមិត្តសញ្ញារបស់រដ្ឋបាលខេត្តរតនគិរី សម្រាប់ប្រើប្រាស់ជាផ្លូវការ។

-រដ្ឋបាលខេត្តកណ្តាល ករណីឈ្មោះ គួច យូផល និងឈ្មោះ អ៊ាវ ហ្គេច ស្នើសុំពិនិត្យ និងដោះស្រាយជូនពួកគាត់អំពីករណីដែលអាជ្ញាធរភូមិ ឃុំ ស្រុក និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមិនគោរព និងអនុវត្តតាមស្មារតីលិខិតលេខ ១៨១៨សជណ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ និងលិខិតលេខ ០២២សជណ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តកណ្តាលពាក់ព័ន្ធនឹងសំណើសុំចុះបញ្ជីក្បាលដីទំហំ ៨ម៉ែត្រ x ៨៦៤ម៉ែត្រ ស្ថិតនៅភូមិស្វាយលាប ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល

-រដ្ឋបាលខេត្តកោះកុង ករណីតំណាងប្រជាពលរដ្ឋ ៧៤៣គ្រួសារ ស្នើសុំជួយជំរុញ និងពន្លឿនការដោះស្រាយជម្លោះដីធ្លីរវាងប្រជាពលរដ្ឋចំនួន ៧៤៣គ្រួសារ ជាមួយក្រុមហ៊ុន កោះកុងស៊ូហ្គើ និងកោះកុង ផ្លេនថេសិនអ៊ីនដាស់ស្ទ្រី ខមផេនី លីមិតធីត របស់លោកឧកញ៉ា លី យ៉ុងផាត់ នៅក្នុងទឹកដីស្រុកបូទុមសាគរ ស្រុកថ្មបាំង និងស្រុកស្រែអំបិល។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ សុខ រឿន, ញ៉ែត សុភាព, ហោ នើង, ឡាវ ទិតយោង, ព្រាប រី និងឈ្មោះ សែម ម៉ៅ តំណាងប្រជាពលរដ្ឋ ១៣៤គ្រួសារ ស្នើសុំជួយអន្តរាគមន៍រកដំណោះស្រាយក្នុងការផ្តល់ដីធ្លីសម្រាប់រស់នៅ និងប្រកបមុខរបរដាំដុះចិញ្ចឹមជីវិតប្រចាំថ្ងៃ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត

-បន្តរៀបចំសម្របសម្រួលដំណើការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី ខេត្ត និងក្រុមការងាររាជរដ្ឋាភិបាលមូលដ្ឋាន

-បន្តរៀបចំ កែសម្រួលនូវប្រព័ន្ធរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត

-រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារសន្និបាតប្រចាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី ខេត្ត និងក្រុមការងាររាជរដ្ឋាភិបាល។

**៤.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យ និងលើកយោបល់ ជូនថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធនឹងការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការបង្កើតភូមិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណីស្នើសុំបង្កើតភូមិថ្មីចំនួន ០២ ស្ថិតក្នុងឃុំណាំតៅ ស្រុកភ្នំស្រុក និងភូមិចំនួន ០៥ ស្ថិតក្នុងឃុំតាគង់ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តតាកែវ ករណីរដ្ឋបាលឃុំកំពង់រាប ឃុំព្រៃល្វា ស្នើសុំបំបែកភូមិ ចំនួន ០៣ ស្ថិតក្នុងឃុំកំពង់រាប និងឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។

-រដ្ឋបាលខេត្តព្រៃវែង ករណីស្នើសុំបំបែកភូមិចំនួន ០៤ភូមិ ស្ថិតនៅក្នុងឃុំកំពង់ពពិល ចំនួន ០១ភូមិ និងឃុំកញ្ចំ ចំនួន ០៣ភូមិ នៃស្រុកពារាំង ខេត្តព្រៃវែង។

-រដ្ឋបាលខេត្តកំពត ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងកំពត និងស្រុកទឹកឈូ។

-រដ្ឋបាលខេត្តសៀមរាប ព្រះវិហារ ឧត្តរមានជ័យ និងខេត្តបាត់ដំបង ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខេត្តសៀមរាប ជាមួយខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង។

**៤.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

-បន្តតាមដាន ត្រួតពិនិត្យអំពីការអនុវត្តលិខិតលេខ ១៩៧៣ស.ជ.ណ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការពង្រឹងការគ្រប់គ្រង ការស្នើសុំគ្រឿងឥស្សរិយយសស្ថាបនាជាតិ និងគោរមងារជាឧកញ៉ាជូនសប្បុរសជន ដែលមានស្នាដៃ និងគុណបំណាច់ក្នុងការជួយកសាងជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង ករណីសំណើសុំគ្រឿងឥស្សរិយយសរបស់រដ្ឋបាលខេត្ត បាត់ដំបង ស្វាយរៀង ខេត្តកំពង់ចាម ខេត្តបន្ទាយមានជ័យ និងខេត្តស្ទឹងត្រែង។

**៤.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

**៤.៤.១-កម្មវិធីគាំទ្រដោយអង្គការ UNICEF**

-បន្តរៀបចំសេចក្តីព្រាងសៀវភៅណែនាំ ស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តរៀបចំសំណើសុំថវិកាអនុវត្តគម្រោងត្រីមាសទី១ឆ្នាំ២០២០

-បន្តចុះតាមដានការអនុវត្តសកម្មភាពសេវាសង្គមនៅរាជធានី ខេត្តគោលដៅ

-បន្តរៀបចំប្រព័ន្ធទិន្នន័យអនឡាញ (Data Base of SNAs) របស់រដ្ឋបាលរាជធានី ខេត្ត។

**៤.៤.២-គម្រោងសាងសង់អគាររដ្ឋបាល អាគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP**

-បន្តតាមដាន និងសម្របសម្រួលទាក់ទងនឹងសំណើសុំថវិកាបន្ថែមទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរក្សាការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់តាមចំនួនដែលបានគ្រោងទុក

-បន្តចុះពិនិត្យ និងតាមដានដំណើរការសាងសង់អគារសាលាស្រុក និងឃុំ សង្កាត់ដំណាក់កាលទី១ និងទី២។

**៤.៥-ការងាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់**

-បន្តតាមដាន ត្រួតពិនិត្យការរៀបចំ និងអនុវត្តថវិការដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់

-បន្តរៀបចំទម្រង់ផ្តល់យោបល់អំពីនីតិវិធីនៃការអនុវត្តគម្រោងក្រុង ស្រុក ឃុំ សង្កាត់

-បន្តធ្វើបច្ចុប្បន្នភាពដំណើរការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០២០-២០២២ និង

-បន្តធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍប្រាំឆ្នាំ ២០២០-២០២៤ របស់រដ្ឋបាលក្រុង ស្រុក

-ត្រៀមរៀបចំកិច្ចប្រជុំស្តីពីស្ថានភាពនៃការគាំទ្ររបស់រដ្ឋបាលរាជធានី ខេត្តដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់លើកទី៣

-បន្តប្រមូល និងរក្សាទុកទិន្នន័យអនុវត្តគម្រោងក្រុង ស្រុក ឃុំ សង្កាត់

-បន្តតាមដានប្រព័ន្ធទិន្នន័យដេញថ្លៃគម្រោងឃុំ សង្កាត់ (BID)

-បន្តជំរុញដំណើរការដេញថ្លៃ និងការចុះកិច្ចសន្យាគម្រោងក្រុង ស្រុក ឃុំ សង្កាត់

-បន្តពង្រឹង និងពន្លឿនការចាត់ចែង ដោះស្រាយពាក្យបណ្តឹងនានាដែលពាក់ព័ន្ធនឹងក្រុង ស្រុក ឃុំ សង្កាត់ ។

**៤.៦-ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

-សហការជាមួយធនាគារពិភពលោក ដើម្បីចុះសិក្សា និងប្រមូលព័ត៌មានអំពីស្ថានភាពនៃការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន និងការគ្រប់គ្រងទីលានចាក់សំរាមនៅក្រុង ស្រុកគោលដៅមួយចំនួនបន្ថែមទៀត

-បន្តសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗ និងលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងដំណើរការរៀបចំផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

-ផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-រៀបចំដាក់ឱ្យដំណើរការសាកល្បងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូល តែមួយរាជធានី ខេត្ត

-រៀបចំសេចក្តីណែនាំស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលឃុំ សង្កាត់

-ចុះសិក្សាអំពីជម្រើសនៃការរៀបចំការិយាល័យច្រកចេញចូលតែមួយ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាល នៅថ្នាក់ក្រុង ស្រុក ខណ្ឌ

-សិក្សាអំពីលទ្ធភាពដាក់ឱ្យដំណើរការការផ្តល់សេវាអត្តសញ្ញាណកម្មតាមយន្តការច្រកចេញចូលតែមួយ

-បន្តផ្សព្វផ្សាយអំពីតួនាទីភារកិច្ច សមត្ថកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដល់ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធ។

**៥-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ដើម្បីលើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ននានា អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យ និងលើកយោបល់លើករណីដូចខាងក្រោម៖

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ករណីស្នើសុំជួយអន្តរាគមន៍ទៅរដ្ឋបាលខេត្តកំពង់ធំ ករណីសកម្មភាពការឈូសឆាយព្រៃលិចទឹក នៅចំណុចក្រពើក្រមុំចំណុចដូនកាយ និងចំណុចក្បាលស្ទឹង ក្នុងឃុំចំណារក្រោម និងឃុំសំព្រជ ស្រុកស្ទោង ខេត្តកំពង់ធំ។

-វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ករណីស្នើសុំអនុញ្ញាតចុះធ្វើការអង្កេតសម្រាប់ការសិក្សាស្តីពី"ការវិភាគទស្សនយេនឌ័រលើភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនិងអាហារូបត្ថម្ភ៖ ប្រទេសកម្ពុជា និងប្រទេសឥណ្ឌាភាគខាងត្បូង"។

-ក្រុមហ៊ុន ហារ៉ស់បៃហ្វត ឯ.ក ករណីស្នើសុំចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ឃើញទៅលើស្ថានភាពដែលពាក់ព័ន្ធនឹងសហគមន៍ក្នុងប្រទេសកម្ពុជា ដែលនឹងត្រូវចុះតាមរាជធានីភ្នំពេញ និងតាមខេត្ត។

**៦-ការងារតាមវិស័យផ្សេងៗ**

**៦.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងប័ណ្ណព្រំដែន**

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊្វូវ និងព្រែកជ្រៃធំ-ព្រែកប៊ិញឃី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។

-បន្តពិនិត្យ និងលើកយោបល់ ចំពោះករណីសកម្មភាពបូមខ្សាច់របស់ភាគីវៀតណាម នៅក្បែរតំបន់ព្រំដែនកម្ពុជា-វៀតណាម ស្ថិតនៅភូមិក្អមសំណក្រោម ឃុំក្អមសំណ ស្រុកលើកដែក ខេត្តកណ្តាល។

-បន្តតាមដាន និងគាំទ្រដល់រដ្ឋបាលខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវដល់ដំណើរការផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវប្រើប្រាស់ ព្រមទាំងបន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការផ្តល់សេវាប័ណ្ណព្រំដែននៅក្រុង ស្រុក និងច្រកទ្វារព្រំដែននៃបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ។

-បន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យប័ណ្ណព្រំដែនកម្ពុជាឱ្យមានភាពប្រសើរ និងប្រសិទ្ធភាពខ្ពស់។

**៦.២-ការងារចងសម្ព័ន្ធមេត្រីភាពនិងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តពិនិត្យលើកយោបល់លើសំណើរបស់រដ្ឋបាលខេត្តសៀមរាប ករណី៖

- សំណើគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលខេត្តក្រុងសៀមរាប ខេត្តសៀមរាបចុះហត្ថលេខាលើអនុស្សរណៈកិច្ចព្រមព្រៀងសម្ព័ន្ធមេត្រីភាពជាមួយក្រុងតាថុង ខេត្តសានស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។
- សំណើគោលការណ៍អនុញ្ញាតរដ្ឋបាលខេត្តសៀមរាបចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតសម្ព័ន្ធមេត្រីភាពជាមួយក្រុងស៊ីអាន ខេត្តសានស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៧ ដែលភាគីថៃទទួលធ្វើជាម្ចាស់ផ្ទះក្នុងឆ្នាំ២០២០។

-បន្តពិនិត្យ និងលើកយោបល់ករណីឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា គ្រោងនឹងទៅបំពេញទស្សនកិច្ចផ្លូវការនៅខេត្តកំពង់ធំ។

-បន្តសម្របសម្រួលការងាររៀបចំកិច្ចប្រជុំក្រុមការងារចម្រុះស្តីពីច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាម។

-បន្តសម្របសម្រួលលើការងាររៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាមលើកទី១១។

-បន្តពិនិត្យ និងលើកយោបល់ ករណីសុំជួយអន្តរាគមន៍ទប់ស្កាត់និងហាមឃាត់ការនាំចូលបន្លែ-ផ្លែឈើដែលមានជាតិគីមីពុលពីបរទេសចូលមកព្រះរាជាណាចក្រកម្ពុជា។

-បន្តសម្របសម្រួលលើករណីស្នើសុំរបាយការណ៍លទ្ធផលកិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម។

**៦.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ**

អគ្គនាយកដ្ឋានរដ្ឋបាល បន្តពិនិត្យ និងលើកយោបល់ចំពោះសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោមៈ

-**រដ្ឋបាលរាជធានីភ្នំពេញ** ករណីស្នើសុំស្លាកលេខរដ្ឋសម្រាប់ម៉ូតូម៉ាក Suzuki Smash 2019 ចំនួន ០៣ គ្រឿង ដោយចុះបញ្ជីសារពើភ័ណ្ឌជាទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលរាជធានីភ្នំពេញ។

-**រដ្ឋបាលរាជធានី ខេត្ត** ករណីសំណើរផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍ ឆ្នាំ២០១៩ ឆ្នាំ២០២០ និងផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ (២០២០-២០២៤) របស់រដ្ឋបាលរាជធានី ខេត្ត។

-**រដ្ឋបាលខេត្តមណ្ឌលគិរី** ករណីស្នើសុំគោលការណ៍រៀបចំតំបន់រដ្ឋបាលស្រុកអូររាំងថ្មី ដោយកាត់ដីទំហំ ២១៧,៨៣២ ហិកតាស្ថិតនៅក្នុងភូមិពូរ៉ាង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។

-**រដ្ឋបាលខេត្តកំពង់ចាម** ករណីសំណើសុំគោលការណ៍ជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់រដ្ឋបាលសង្កាត់កំពង់ចាម (អតីតសាលាឃុំកំពង់ចាម) ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

-**រដ្ឋបាលខេត្តក្រចេះ** ករណីធ្វើសេចក្តីរាយការណ៍អំពីករណីសំណើសុំទិញដីទំហំ ៧៨.៤០០ម៉ែត្រការ៉េ ស្ថិតនៅភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ។

-**រដ្ឋបាលខេត្តព្រះវិហារ** ករណីស្នើសុំស្លាកលេខរថយន្ត ០១គ្រឿង របស់រដ្ឋបាលខេត្តព្រះវិហារ។

-រៀបចំរបាយការណ៍ស្តីពីការចុះត្រួតពិនិត្យការអនុវត្តគម្រោងអភិវឌ្ឍឆ្នាំ២០១៩ក្នុងអំឡុងពេលកំពុងអនុវត្ត និងធ្វើលិខិតជម្រាបទៅរដ្ឋបាលរាជធានី ខេត្តឲ្យពន្លឿនការកសាងផែនការអភិវឌ្ឍរយៈប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងការរៀបចំគម្រោងអភិវឌ្ឍប្រចាំឆ្នាំឲ្យបានទាន់ពេលវេលា។

**៦.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ**

**៦.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**

-បន្តលើកយោបល់អំពីការសុំចុះឈ្មោះ សុំបើកទីស្នាក់ការសាខា សុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មីនៃចេនាសម្ព័ន្ធ សុំប្តូរទីស្នាក់ការកណ្តាល សុំប្តូរឈ្មោះ សុំធ្វើវិសោធនកម្មលក្ខន្តិកៈ សុំលុបឈ្មោះ ការផ្អាកសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំណើផ្សេងៗដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច

-បន្តលើកយោបល់អំពីការសុំតម្កល់សំណុំឯកសារ អំពីការផ្លាស់ប្តូរសមាសភាពរចនាសម្ព័ន្ធ និងការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិច

-បន្តគាំទ្រកិច្ចដំណើរការរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តធ្វើបច្ចុប្បន្នភាព និងបូកសរុបនូវរបាយការណ៍សកម្មភាព និងការផ្តល់លេខគណនីរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តតាមដាន ប្រមូលព័ត៌មានពីគ្រប់បណ្តាញព័ត៌មានសង្គមពាក់ព័ន្ធនឹងការធ្វើសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តពិនិត្យ និងដោះស្រាយពាក្យបណ្តឹង ឬសំណើនានារបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តចូលរួមកិច្ចប្រជុំជាមួយក្រុមការងារវាយតម្លៃអញ្ញមញ្ញ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងចូលរួមប្រជុំជាមួយតំណាងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់(APG)

-បន្តចូលរួមកិច្ចប្រជុំជាមួយក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ICRP-JG) នៃក្រុមការងារហិរញ្ញវត្ថុ (FATF)

-រៀបចំរបាយការណ៍ជូនទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិអំពីវឌ្ឍនភាពសមិទ្ធផលឧត្តមានុវត្តន៍ និងបញ្ហាប្រឈមពាក់ព័ន្ធនឹងសិទ្ធិសេរីភាពនៃការជួបជុំដោយសន្តិវិធី និងសិទ្ធិក្នុងការបង្កើតសមាគម ដើម្បីត្រៀមចូលរួមក្នុងសម័យប្រជុំលើកទី៤៤ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ

-បន្តរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាសំណើ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិលក្នុងការធ្វើ វិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**៦.៤.២-ការងារគណបក្សនយោបាយ**

-បន្តពិនិត្យ លើកយោបល់ អំពីការសុំបង្កើត ឬការសុំចុះបញ្ជីនិងសំណើនានារបស់គណបក្សនយោបាយ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច

-បន្តពិនិត្យ លើកយោបល់ នូវរាល់សំណើពាក់ព័ន្ធនិងការផ្លាស់ប្តូរ ឬការប្រែប្រួលនានារបស់គណបក្សនយោបាយ

-រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះគណបក្សនយោបាយដែលបានបង្កើត បានចុះបញ្ជី និងត្រូវបានលុបឈ្មោះ

-បន្តតាមដានពិនិត្យបូកសរុបប្រមូលព័ត៌មាន ពីគ្រប់បណ្តាញព័ត៌មានសង្គម និងរបាយការណ៍របស់រដ្ឋបាលរាជធានី ខេត្ត ចំពោះគណបក្សនយោបាយ ដែលបានធ្វើសកម្មភាពផ្ទុយពីលក្ខន្តិកៈ ច្បាប់ស្តីពីគណបក្សនយោបាយ និង លិខិតបទដ្ឋានគតិយុត្តជាធរមាននានា

-បន្តពិនិត្យ និងសិក្សាអំពីការធ្វើវិសោធកម្មប្រកាសរួមលេខ ០០៧សហវ.ហ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីអាករចុះបញ្ជីគណបក្សនយោបាយ រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ពិនិត្យ និងដោះស្រាយពាក្យបណ្តឹង ឬសំណើនានារបស់គណបក្សនយោបាយ

-ត្រៀមបោះពុម្ពសៀវភៅច្បាប់ស្តីពីគណបក្សនយោបាយចំនួន ៥.០០០ក្បាល ដើម្បីធ្វើការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានា៕

អគ្គនាយក

ប្រាក់ សំអឿន

__ចម្លងជូន៖__

-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

(ជូនជ្រាបជាសេចក្តីរាយការណ៍)

-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ

-អគ្គស្នងការដ្ឋាននគរបាលជាតិ

-អគ្គនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

-អគ្គាធិការដ្ឋាន

-អគ្គនាយកដ្ឋានពន្ធនាគារ

-គ្រប់នាយកដ្ឋានចំណុះអ.រ.ប

"ដើម្បីជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ